ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពជាតិ
# ស្តីពី
# សុខភាពសិក្សា
# ២០២១ - ២០៣០

បានទទួលការឯកភាពពីគ.អ.ស.ស.
នាសម័យប្រជុំថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

# មាតិកា

ទំព័រ

**១- សារបាន** ........................................................ 1

១.១- គោលនយោបាយ ........................................................ 3

១.២- ស្ថានភាព ........................................................ 3

១.៣- បញ្ហាអាទិភាព ........................................................ 20

**២- យុទ្ធសាស្ត្រ** ........................................................ 21

**៣- ផែនការសកម្មភាព** ........................................................ 25

៣.១- បរិយាយសង្ខេបពីវិសាលភាពនៃផែនការ ........................................................ 25

៣.២- តារាងអនុវត្តការងារ ........................................................ 26

៣.៣ សូចនាករស្នូលនៃយុទ្ធសាស្ត្រនីមួយៗ ........................................................ 85

**៤- កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត** ........................................................ 88

**៥- គម្រោងចំណាយ** ........................................................ 92

**៦- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ........................................................ 94

**៧- សេចក្តីសន្និដ្ឋាន** ........................................................ 95

**អក្សរកាត់** ........................................................ 96

## អារម្ភកថា

ប្រទេសកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលថ្មីមួយនៃការអភិវឌ្ឍគ្រប់វិស័យពិសេសវិស័យអប់រំឆ្លើយតបទៅនឹងបរិបទតំបន់និងសកលលោក ស្របតាមបំណងប្រាថ្នាលើកកម្ពស់គុណភាព សមធម៌ បរិយាបន្ននិងការសិក្សាពេញមួយជីវិតក្នុងក្របខណ្ឌនិងវិសាលភាពគ្របដណ្តប់ទូលំទូលាយជាងមុន។ គុណតម្លៃស្នូលនៃវិស័យអប់រំគឺអភិវឌ្ឍធនធានមនុស្សឱ្យបានពេញលេញ មានចំណេះដឹង សុខភាពល្អ សមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត នវានុវត្តន៍ ស្មារតីសហគ្រិនភាព និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកការអភិវឌ្ឍវិស័យឧស្សាហកម្មដែលជួយជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងការប្រកួតប្រជែងនិងលើកកម្ពស់ផលិតភាពឆ្ពោះទៅសម្រេចនូវចក្ខុវិស័យ អភិវឌ្ឍន៍កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។

ក្នុងបរិបទនេះការលើកកម្ពស់សុខភាពសិក្សាមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំនិងមិនអាចខ្វះបានក្នុងការចូលរួមអភិវឌ្ឍធនធានមនុស្ស ដោយផ្តើមចេញពីការគាំទ្រការអនុវត្តតាមបែបពហុវិស័យបញ្ចូលគ្នាឆ្លើយតបនឹងគោលនយោបាយជាតិស្តីពីសុខភាពសិក្សាដែលទទួលបានការឯកភាពក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩។

ផែនការសកម្មភាពជាតិស្តីពីសុខភាពសិក្សាឆ្នាំ២០២១-២០៣០ បានរៀបចំឡើងដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីសុខភាពសិក្សា ផ្តោតលើសកម្មភាពជាអាទិភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រទាំង៩ប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា រួមទាំងអប់រំបច្ចេកទេស វិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិតស្របតាមយុគសម័យបច្ចេកទេសឌីជីថលក្នុងការបង្កើនសេដ្ឋកិច្ចនិងសុខុដុមជីវិតបុគ្គលនិងសង្គម។ ផែនការសកម្មភាពជាតិនេះបំពេញតួនាទីជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្តសកម្មភាពលើកកម្ពស់សុខភាពសិក្សាដោយផ្សារភ្ជាប់ទំនាក់ទំនងរវាងគោលនយោបាយ យុទ្ធសាស្ត្រ ធនធានហិរញ្ញវត្ថុ មានភាពប្រទាក់ក្រឡា និងមានសង្គតិភាព ទៅនឹងកម្មវិធីមានស្រាប់ ដើម្បីជានាបាននូវការទទួលខុស ត្រូវក្នុងដែនសមត្ថកិច្ចរៀងៗ ខ្លួនក្នុងការរួម ចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ខាងមុខ។

ដើម្បីឱ្យការអនុវត្តផែនការសកម្មភាពជាតិនេះទទួលបានជោគជ័យចាំបាច់ត្រូវមានការប្តេជ្ញាចិត្តរួមគ្នារវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ឆ្លើយតបទៅនឹងការអភិវឌ្ឍធនធានមនុស្សឱ្យក្លាយជាពលរដ្ឋសកលស្របតាមបរិបទនៃការអភិវឌ្ឍកម្ពុជា។

ថ្ងៃចន្ទ ១៤រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**និងជាប្រធានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

## ១- សារធាន

ការលើកកម្ពស់សុខភាពសិក្សា គឺជាកត្តាដ៏សំខាន់មួយដែលរួមចំណែកដល់ការធានាបាននូវការសិក្សាប្រកបដោយគុណភាព និងបង្កើនអត្រាបញ្ចប់ការសិក្សា ដើម្បីសម្រេចនូវគោលដៅនៃការអប់រំ។ អ្នកសិក្សាមានសុខភាពល្អ នឹងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៀន ជាពិសេសជួយបង្កើនអត្រាគង់វង្ស និងបង្កើនភាពវៃឆ្លាតរបស់អ្នកសិក្សា។ ផ្ទុយទៅវិញ បើសុខភាពអ្នកសិក្សាមានបញ្ហា នឹងក្លាយជាឧបសគ្គចម្បងមួយរារាំងពួកគេមិនឱ្យទទួលបាននូវការសិក្សាល្អប្រសើរនៅក្នុងអំឡុងពេលសិក្សា។

ដោយមើលឃើញពីសារៈសំខាន់នេះ អង្គការសុខភាពពិភពលោក បានចេញសេចក្ដីថ្លែងការណ៍ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតគោលនយោបាយ ច្បាប់ គោលការណ៍ណែនាំ សម្រាប់លើកកម្ពស់សុខភាពតាមសាលារៀន។ ទន្ទឹមនឹងនេះដែរ សន្និសីទពិភពលោកស្ដីពីការអប់រំសម្រាប់ទាំងអស់គ្នា នៅទីក្រុងដាកា ប្រទេស សេណេហ្គាល់ ឆ្នាំ២០០០ អង្គការយូណេស្កូ អង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ អង្គការកម្មវិធីស្បៀងអាហារពិភពលោក អង្គការយូអិនអេដស៍ បានចេញសេចក្ដីថ្លែងការណ៍ឱ្យប្រទេសកំពុងអភិវឌ្ឍ ផ្ដោតការយកចិត្តទុកដាក់លើការប្រមូលធនធានសម្រាប់សុខភាពសិក្សាប្រកបដោយប្រសិទ្ធភាព។

ក្នុងដំណើរវិវត្តជាបន្តបន្ទាប់ ក្របខណ្ឌសកម្មភាពពាក់ព័ន្ធទៅនឹងសុខភាពសិក្សាត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្ដីប្រកាសនៃវេទិកាអប់រំពិភពលោក នៅទីក្រុង Incheon ប្រទេសកូរ៉េខាងត្បូង នាឆ្នាំ២០១៥ ស្ដីពីចក្ខុវិស័យអប់រំឆ្នាំ២០៣០ ឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាបន្ន សមធម៌ និងសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ នៅឆ្នាំ២០១៥ ប្រទេសនៅក្នុងតំបន់អាស៊ាន បានកំណត់ "ការអប់រំនិងគាំពារកុមារដោយមិនទុកកុមារណាម្នាក់ចោល ពិសេសកុមារដែលបាត់បង់ឱកាស" ជាអាទិភាពមួយក្នុងចំណោមអាទិភាពទាំងប្រាំពីរនៅក្នុងរបៀបវារៈសំខាន់សម្រាប់ឆ្នាំ២០១៥-២០៣៥។ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ សន្និសីទពិភពលោកលើកទី៩ ស្ដីពីការលើកកម្ពស់សុខភាព នៅទីក្រុងសៀងហៃ បានអំពាវនាវជាថ្មីម្ដងទៀតឱ្យរដ្ឋជាសមាជិកទាំងអស់ ត្រូវបង្កើនការវិនិយោគបន្ថែមដោយមានការចូលរួមពីគ្រប់វិស័យ ទាំងរដ្ឋ ឯកជន និងសង្គមស៊ីវិល ក្នុងការលើកកម្ពស់សុខភាពនិងសុខុមាលភាព ដើម្បីធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ មកដល់ពេលនេះ មានប្រទេសជាច្រើននៅក្នុងតំបន់បានបង្កើតជាគោលនយោបាយនិងគោលការណ៍ណែនាំនានា ស្ដីពីសុខភាពសិក្សា។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញចក្ខុវិស័យក្នុងការប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។ ដើម្បីសម្រេចចក្ខុវិស័យខាងលើ រាជរដ្ឋាភិបាល បានកំណត់យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ នៅមុំទី១ អំពីការអភិវឌ្ឍធនធានមនុស្ស និងមុំទី៣ អំពីការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ ក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណ

ភាព ផលិតភាពការងារខ្ពស់ និងសុខភាពរឹងមាំ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការលើកកម្ពស់សុខភាពសិក្សា ដោយបានដាក់ចេញជាសំណុំយុទ្ធសាស្ត្រនិងសកម្មភាពអន្តរកម្មរវាងគ្រឹះស្ថានសិក្សានិងសេវាកម្មសុខភាពនានា ដើម្បីលើកកម្ពស់សុខភាព តាមរយៈការអប់រំសុខភាព ការបង្ការជំងឺ ការផ្តល់សេវាសុខភាពចាំបាច់ ការលើកកម្ពស់អនាម័យ បរិស្ថាន និងការផ្គត់ផ្គង់ទឹកស្អាតដល់បុគ្គលិកអប់រំនិងអ្នកសិក្សាជាដំណាក់កាលៗ។

ក្រសួងអប់រំ យុវជន និងកីឡា នៅឆ្នាំ២០០៦ បានដាក់ចេញគោលនយោបាយ ស្តីពីសុខភាពសិក្សា ក្នុងគោលបំណងផ្តល់សេវាថែទាំសុខភាពចាំបាច់ ការអប់រំសុខភាព ការលើកកម្ពស់បរិស្ថានសាលារៀន និងការចូលរួមពីអ្នកពាក់ព័ន្ធ។ ទោះបីជាក្រសួង បានខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សុខភាពសិក្សា ដូចបានរៀបរាប់ខាងលើក្តី ក៏ការអនុវត្តការងារសុខភាពសិក្សាមិនទាន់មានភាពគ្រប់ជ្រុងជ្រោយ ជាពិសេសមិនទាន់ទទួលបានការចូលរួមផុលផុសពីស្ថាប័នពាក់ព័ន្ធនៅឡើយ។ យោងលើបរិបទនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីសុខភាពសិក្សា ហើយទទួលបានការឯកភាពនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ដែលជាផែនទីបង្ហាញផ្លូវក្នុងការចូលរួមអនុវត្តពេញលេញតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការអប់រំ និងដើម្បីឆ្លើយតបភាពរីកចម្រើននិងតម្រូវការដ៏ទទូចរបស់ប្រជាពលរដ្ឋ ព្រមទាំងជំរុញការអនុវត្តសិទ្ធិមនុស្ស។ គោលនយោបាយនេះ តម្រូវឱ្យមានការចូលរួមជាពហុវិស័យពាក់ព័ន្ធប្រកបដោយសង្គតិភាព និងអាចអនុវត្តបាន ក្នុងការចូលរួមអភិវឌ្ឍមូលធនមនុស្សដែលជាបំណងប្រាថ្នាដ៏ទទូចរបស់ប្រជាជនកម្ពុជា ដើម្បីកសាងកម្ពុជាក្លាយជាអរិយប្រទេសនាពេលអនាគត។

ដើម្បីប្រែក្លាយគោលនយោបាយជាតិស្តីពីសុខភាពសិក្សាទៅជាការអនុវត្តជាក់ស្តែង ចាំបាច់ត្រូវមានផែនការសកម្មភាពជាតិស្តីពីសុខភាពសិក្សាមួយមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបាន ក្នុងនោះផ្តោតជាសំខាន់លើសកម្មភាពជាអាទិភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទាំង៩ប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ ស្របតាមយុគសម័យបច្ចេកទេស ឌីជីថល ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខុដុមជីវិតបុគ្គល និងសង្គម។ ផែនការសកម្មភាពជាតិស្តីពីសុខភាពសិក្សាឆ្នាំ២០២១-២០៣០នេះ ត្រូវបានរៀបចំឡើងក្នុងគោលដៅផ្សារភ្ជាប់ទំនាក់ទំនងរវាងគោលនយោបាយ យុទ្ធសាស្ត្រ ធនធានហិរញ្ញវត្ថុ តាមរយៈសកម្មភាពភាពប្រទាក់ក្រឡាគ្នា និងមានសង្គតិភាពទៅនឹងកម្មវិធីមានស្រាប់ ដោយមានការពិគ្រោះយោបល់ និងការពិភាក្សាល្អិតល្អន់រវាងក្រសួង ស្ថាប័ន អ្នកពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ដើម្បីធានាបាននូវការបំពេញមុខងារ តួនាទីភារកិច្ច និងការទទួលខុសត្រូវក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន ក្នុងការចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ខាងមុខ។

## ១.១- គោលនយោបាយ

គោលនយោបាយជាតិស្តីពីសុខភាពសិក្សា មានចក្ខុវិស័យ អភិវឌ្ឍធនធានមនុស្សឱ្យមានលក្ខណៈសម្បត្តិពេញលេញនិងមានសុខភាពល្អ ទាំងកាយសម្បទា ទាំងបញ្ញា ទាំងស្មារតី ដើម្បីអភិវឌ្ឍសង្គមកម្ពុជាប្រកបដោយចីរភាព ព្រមទាំងមានគោលបំណងរួមចំណែកលើកកម្ពស់គុណភាពអប់រំ និងផ្តល់ឱ្យអ្នកសិក្សានិងបុគ្គលិកអប់រំ នូវលទ្ធភាពក្នុងការទទួលបាននូវសុខភាពល្អនិងសុខុមាលភាព ដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្តានុពល។

ដើម្បីសម្រេចចក្ខុវិស័យនិងគោលបំណងខាងលើ គោលនយោបាយជាតិស្តីពីសុខភាពសិក្សា មានគោលដៅជំបូងដោយផ្តោតលើការៈ

- លើកកម្ពស់ការផ្តល់សេវាសុខភាពចាំបាច់ដល់អ្នកសិក្សានិងបុគ្គលិកអប់រំ
- លើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ
- លើកកម្ពស់បរិស្ថានសិក្សាប្រកបដោយបរិយាបន្ន
- បណ្តុះវប្បធម៌ថែរក្សាសុខភាពផ្ទាល់ខ្លួន គ្រួសារ និងសង្គម
- ជំរុញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពសិក្សា។

ក្នុងការធ្វើឱ្យសម្រេចនូវគោលដៅខាងលើ គោលនយោបាយជាតិនេះ មានយុទ្ធសាស្រ្តចម្បងៗចំនួន៩ និងយុទ្ធសាស្រ្តរងចំនួន៥៥។

## ១.២- ស្ថានភាព

ក្នុងជំរឿនប្រជាជនឆ្នាំ២០១៩ ប្រទេសកម្ពុជាមានប្រជាជនសរុប ១៥ ៥៥២ ២១១នាក់ ក្នុងនោះប្រុសមានចំនួន ៧ ៥៧១ ៨៣៧នាក់ ស្មើនឹង ៤៨,៧ភាគរយ និងស្រីមានចំនួន ៧ ៩៨០ ៣៧៤នាក់ ស្មើនឹង ៥១,៣ភាគរយ។ រយៈពេល១១ឆ្នាំ ចន្លោះឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩ ចំនួនប្រជាជនបានកើនឡើង ២ ១៥៦ ៥២៩នាក់ ស្មើនឹង១៦,១ភាគរយ។ ទំហំគ្រួសារជាមធ្យមនៅថេរ៤,៣នាក់ តាំងពីឆ្នាំ២០០៨។ ប្រជាជន៦០,៦ភាគរយរស់នៅតាមទីជនបទនិងប្រមាណ៣៩,៤ភាគរយរស់នៅទីប្រជុំជន។ អ្នកនិយាយភាសាកំណើតជនជាតិដើមភាគតិចមានចំនួនប្រមាណ២,៩ភាគរយនៃចំនួនប្រជាជនសរុប។ កុមារក្នុងវ័យសិក្សា ត្រូវបានប្រមាណថាជាង ៩០ភាគរយ នៃប្រជាជនដែលមានអាយុចាប់ពី ៦-១១ឆ្នាំ និងអាយុ ១២-១៤ឆ្នាំ បច្ចុប្បន្នកំពុងចូលរៀន ។

រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តរបៀបវារៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (គ.អ.ច) ២០១៦-២០៣០ ជាមួយនឹងប្រទេសជាសមាជិកអង្គការសហប្រជាជាតិ នៅក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់មហាសន្និបាតអង្គការសហប្រជាជាតិកាលពីខែកញ្ញា ឆ្នាំ២០១៥។ ក្នុងជំណាក់កាលថ្មីនេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តការខិតខំរបស់ខ្លួន ដើម្បីធ្វើមូលដ្ឋាននីយកម្មសកលនៃគ.អ.ច ឱ្យស្របទៅនឹងបរិបទកម្ពុជាដែលហៅថាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក)។ គ.អ.ច.ក

មានគោលដៅចំនួន១៨ ចំណុចដៅចំនួន៨៨ និងសូចនាករសរុបចំនួន១៤៨ ក្នុងនោះ សូចនាករថ្នាក់ជាតិមានចំនួន៩៦។ គោលដៅទី៤ ក្នុងចំណោមគោលដៅទាំង១៨ គឺ "ធានាការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប" ក្នុងនោះចំណុចដៅ ៤.a មានបញ្ជាក់ច្បាស់ថា កសាងនិងធ្វើឱ្យប្រសើរឡើងនូវសម្ភារៈបរិក្ខារអប់រំដែលធ្វើឱ្យមានភាពប្រែប្រួលដល់កុមារ អ្នកបាត់បង់សមត្ថភាពពលកម្ម យេនឌ័រ និងផ្តល់នូវសុវត្ថិភាព គ្មានអំពើហិង្សា មានបរិស្ថាននៃការសិក្សាប្រកបដោយបរិយាបន្ន និងប្រសិទ្ធភាពសម្រាប់ប្រជាជនគ្រប់រូប។ ចំណុចដៅនេះមានសូចនាករចំនួន៣គឺ៖ ទី១. សមាមាត្រនៃសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា និងសាលាមធ្យមសិក្សាដែលមានឧបករណ៍ទឹកស្អាតសម្រាប់បរិភោគ លទ្ធផលដៅ ៤៤,៧ភាគរយ នាឆ្នាំ២០២០ និង៨០,០ភាគរយ នាឆ្នាំ២០៣០ ទី២. សមាមាត្រនៃសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា និងសាលាមធ្យមសិក្សាដែលមានបង្គន់អនាម័យប្រើប្រាស់ លទ្ធផលដៅ ៧១,៦ភាគរយ នាឆ្នាំ២០២០ និង១០០ភាគរយ នាឆ្នាំ២០៣០ និងសូចនាករទី៣. ភាគរយនៃសាលាបឋមសិក្សា និងមធ្យមសិក្សាដែលមានជម្រាលសម្រាប់សិស្សពិការ លទ្ធផលដៅ៦,៧ភាគរយ នាឆ្នាំ ២០២០ និង២០,០ភាគរយ នាឆ្នាំ២០៣០។ គោលដៅទី៦ "ធានាឱ្យមានទឹកនិងអនាម័យ និងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប" ចំណុចដៅសម្រាប់គោលដៅទី៦នេះ គឺត្រឹមឆ្នាំ២០៣០ ត្រូវ៖ ១. សម្រេចនូវការទទួលបានសកលកម្មនិងសមធម៌នូវសុវត្ថិភាពនិងសមស្របទឹកបរិភោគសម្រាប់ប្រជាជនទាំងអស់ ២. សម្រេចនូវការទទួលបានគ្រប់គ្រាន់និងសមធម៌នូវអនាម័យសម្រាប់ប្រជាជនគ្រប់រូប និងបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល ផ្តោតការយកចិត្តទុកដាក់លើតម្រូវការរបស់ស្ត្រី កុមារី និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ ៣. ធ្វើឱ្យប្រសើរឡើងគុណភាពទឹក ដោយកាត់បន្ថយការបំពុល ការលុបបំបាត់ការចោលសំរាម និងកាត់បន្ថយឱ្យនៅកម្រិតទាបបំផុតនៃការចោលសម្ភារៈ និងសារធាតុជាតិគីមីដែលមានគ្រោះថ្នាក់ កាត់បន្ថយឱ្យនៅពាក់កណ្តាលសមាមាត្រនៃសំណល់រាវដែលមិនបានសម្អាត និងបង្កើនឱ្យបានច្រើនវត្ថុធាតុដើមកើតឡើងវិញ និងការប្រើប្រាស់ឡើងវិញប្រកបដោយសុវត្ថិភាពជាសកល ៤. ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគាំទ្រការកសាងសមត្ថភាពដល់បណ្តាប្រទេសកំពុងអភិវឌ្ឍក្នុងកម្មវិធី និងសកម្មភាពពាក់ព័ន្ធទឹកនិងអនាម័យរួមទាំងបច្ចេកវិទ្យាប្រមូលទឹក បន្សាបទឹកប្រៃ ប្រសិទ្ធភាពទឹក សម្អាតសំណល់រាវ កែច្នៃ និងប្រើប្រាស់ឡើងវិញ។

អត្រាអក្ខរភាពសម្រាប់ភាសាណាមួយក្នុងចំណោមប្រជាជនទូទៅអាយុចាប់ពី៧ឆ្នាំឡើង បានកើនឡើងដល់៨៨,៥ភាគរយ នៅក្នុងឆ្នាំ២០១៩ ដែលជាលទ្ធផលនៃការខិតខំប្រឹងប្រែងអស់ជាច្រើនឆ្នាំរបស់រាជរដ្ឋាភិបាលនៃការវិនិយោគលើវិស័យអប់រំ។ ក្នុងឆ្នាំសិក្សា២០១៩-២០២០ ប្រទេសកម្ពុជាមានគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ ចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាទុតិយភូមិ និងអប់រំបច្ចេកទេសសរុប១៣ ៤៩៨ ក្នុងនោះមត្តេយ្យសិក្សាចំនួន៤៤០៩ បឋមសិក្សាចំនួន៧ ២៨២ មធ្យមសិក្សាបឋមភូមិចំនួន១ ២៤៧ មធ្យមសិក្សាទុតិយភូមិចំនួន៥៤៤ មធ្យមសិក្សាបច្ចេកទេស

ចំនួន១៦។ អ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈសរុប៣ ២១២ ០៧២នាក់ ស្រី៤៩,៧ភាគរយ ក្នុងនោះមត្តេយ្យសិក្សាមាន២៣២ ២០៧នាក់ ស្រី៤៩,៨ភាគរយ បឋមសិក្សាមាន២ ០២៣ ៤៧៣ ស្រី៤៧,៩ភាគរយ មធ្យមសិក្សាបឋមភូមិមាន៦១៨ ៩៦៨ ស្រី៥២,៦ភាគរយ មធ្យមសិក្សាទុតិយភូមិមាន៣៣៤ ៧១២ ស្រី៥៤,៨ភាគរយ និងមធ្យមសិក្សាអប់រំបច្ចេកទេសមាន២ ៧១២នាក់ ស្រី៣៨,៤ភាគរយ។ លើសពីនេះ មានមត្តេយ្យសហគមន៍ចំនួន៣ ០៦៤កន្លែង មានសិស្សចំនួន៧២ ៤១៤នាក់ ស្រី៥១,២ភាគរយ។ វិស័យឯកជនបានចូលរួមចំណែក៧,១ភាគរយ ដោយមានគ្រឹះស្ថានសិក្សាសរុប១ ៤២៦កន្លែង និងសិស្សសរុប២៤៥ ៦៣៧នាក់ ស្រី៤៩,៩ភាគរយ។ លើសពីនេះ គ្រឹះស្ថានឧត្តមសិក្សាមានចំនួន១២៤កន្លែង មាននិស្សិតចំនួន២២២ ៨៧៩នាក់ ស្រី៤៨ភាគរយកំពុងសិក្សា។ ជារួមមានអ្នកសិក្សាសរុប៣ ៧៥៣ ០០២នាក់ ត្រូវការសេវាសុខភាពសិក្សា នៅតាមគ្រឹះស្ថានសិក្សារបស់ពួកគេដែលកំពុងសិក្សា នេះមិនទាន់រាប់បញ្ចូល ថ្នាក់អក្ខរកម្ម និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលមាន១ ២៩២កន្លែង មានអ្នកសិក្សាសរុប៣៨ ៤៧៨នាក់ ស្រី៦៥,១ភាគរយ ព្រមទាំងបុគ្គលិកអប់រំគ្រប់កម្រិតសរុប១២១ ៦៨០នាក់ ស្រី៤៦,១៥ភាគរយផងទេ។

ក្នុងរយៈពេល២០ឆ្នាំចុងក្រោយ កម្ពុជាត្រូវបានចាត់ទុកជាប្រទេសមានការវិវឌ្ឍជាវិជ្ជមានគួរឱ្យកត់សម្គាល់មួយក្នុងពិភពលោក ដោយរក្សាបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧ភាគរយជារៀងរាល់ឆ្នាំ លើកលែងតែឆ្នាំមានវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៩។ ចាប់តាំងពីឆ្នាំ២០១៥មក កម្ពុជាបានឆ្លងផុតឋានៈពីប្រទេសដែលមានការអភិវឌ្ឍតិចតួច មកជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយនៅឆ្នាំ២០២០ ចំណូលជាមធ្យមសម្រាប់ប្រជាជនម្នាក់ៗកើនឡើងដល់១ ៦៨៣ដុល្លារអាមេរិក និងត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់១ ៧៧១ដុល្លារអាមេរិក នៅឆ្នាំ២០២១។ ប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្របានធ្លាក់មកនៅត្រឹម១៣,៥ភាគរយ នាឆ្នាំ២០១៤។ ដំណើរឈានឡើងនេះបាននាំមកនូវមោទនភាពជាតិមិនធ្លាប់មានពីមុនមក ព្រមជាមួយនឹងក្តីសង្ឃឹម និងទំនុកចិត្តដ៏មុតមាំសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ក៏ដូចជាសង្គមជាតិទាំងមូលក្នុងការបន្តអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជាឱ្យឈានដល់ដំណាក់ការអភិវឌ្ឍថ្មីមួយទៀត ពោលគឺប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ២០៣០។ តែទោះជាយ៉ាងនេះក៏ដោយ សេដ្ឋកិច្ចកម្ពុជា មានបម្រែបម្រួលឡើងចុះដោយសារឥទ្ធិពលពីខាងក្រៅមួយចំនួន និងការរាតត្បាតនៃជំងឺឆ្លងផងដែរ ជាក់ស្តែងនៅឆ្នាំ២០០៩ កំណើនសេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះក្បែរសូន្យភាគរយ ដោយសារមូលហេតុវិបត្តិហិរញ្ញវត្ថុសកល និងឆ្នាំ២០២០នេះ កំណើនសេដ្ឋកិច្ចកម្ពុជាបានព្យាករណ៍ថាធ្លាក់ចុះមកនៅ -១,៩ភាគរយ ដោយសារវិបត្តិនៃការរាតត្បាតសកលនៃជំងឺកូវីដ១៩។

តាមរបាយការណ៍សមិទ្ធផលសុខាភិបាលនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រជាជនកម្ពុជាគ្រប់វ័យបានទៅរកសេវាព្យាបាលសាធារណៈមានការកើនឡើងជារៀងរាល់ឆ្នាំរហូតដល់ជាង ១៣លានករណីក្នុងមួយឆ្នាំៗ ក្នុងនោះគេសង្កេតឃើញថាជំងឺឆ្លងនៅតែជាបញ្ហាសុខភាពសាធារណៈសំខាន់ជាងគេ។ ជាក់ ស្តែងក្នុងមួយឆ្នាំៗករណីនៃជំងឺឆ្លងចម្បងៗនាំមុខគេចំនួន១០មានចំនួនជាង៤លានករណី ក្នុង

នោះកុមារអាយុក្រោម៥ឆ្នាំមានចំនួនជាង១លានករណី ដែលរួមមានជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាល់ រលាកក្រពះស្រួចស្រាល់ រាករហូតដល់ខ្សោះជាតិទឹក រលាកសួត រលាកផ្លូវដង្ហើមផ្នែកខាងក្រោម រលាកក្រពះរ៉ាំរ៉ៃ រាកមួល រលាកទងសួតស្រួចស្រាល់ គ្រុនពោះវៀន និងភ្នែកក្រហម។

ដោយឡែក កុមាររៀននៅមត្តេយ្យសិក្សានិងបឋមសិក្សា ចំនួនជាង៩០ភាគរយ មានជំងឺពុកធ្មេញដោយមិនបានព្យាបាល ក្នុងចំណោមនោះ៨៦ភាគរយ មានឆ្លងមេរោគរ៉ាំរ៉ៃលើធ្មេញពុកស្រាប់មួយឬលើស (MoH 2011)។ កត្តាសំខាន់នៃរោគពុកធ្មេញនេះបណ្តាលមកពីកង្វះការថែទាំសុខភាពមាត់ធ្មេញចំពោះកុមារ ការដុសសម្អាតធ្មេញមិនបានត្រឹមត្រូវនិងទៀងទាត់ ការអនុញ្ញាតឱ្យកុមារទទួលទានអាហារដែលមានរសជាតិផ្អែម។ វិធានការឆ្លើយតបមួយចំនួនមានប្រសិទ្ធភាពដែលកំពុងអនុវត្តដូចជា ការអនុវត្តការដុសសម្អាតធ្មេញ ការលាបថ្នាំក្លុយអរវាយ និងការបិទចង្អូរធ្មេញកុមារនៅតាមសាលាមត្តេយ្យនិងបឋមសិក្សា បម្រាមទទួលទានភេសជ្ជៈនិងអាហារផ្អែមខ្លាំងជាដើម។ តែទោះជាយ៉ាងណាវិធានការទាំងនោះ មិនទាន់បានរៀបចំឱ្យបានទូលំទូលាយនៅឡើយ ហើយភាគច្រើនពឹងផ្អែកលើជំនួយពីដៃគូ និងវិស័យឯកជន។

ដោយឡែកជំងឺដង្កូវព្រូនឆ្លងតាមដី (STH) បានចូលរួមចំណែកធ្វើឱ្យកុមារមានបញ្ហាកង្វះអាហារូបត្ថម្ភ ស្លេកស្លាំង និងមិនផ្ចង់អារម្មណ៍ក្នុងការសិក្សារៀនសូត្រ។ ចាប់តាំងពីឆ្នាំ២០០៤មកក្រសួងសុខាភិបាលបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយស្តីពីការ ផ្តល់ថ្នាំទម្លាក់ព្រូន២ដងក្នុង១ឆ្នាំ ចំពោះសិស្សានុសិស្សទាំងអស់នៅតាមសាលាបឋមសិក្សា បានធ្វើឱ្យអត្រាប្រេវ៉ាឡង់នៃជំងឺដង្កូវព្រូនឆ្លងតាមដី ចំពោះកុមារបឋមសិក្សាមានការថយចុះគួរឱ្យកត់សម្គាល់ពីចំនួនជិត៨០ភាគរយ មកនៅ១៦,៧ភាគរយនៅឆ្នាំ២០២០ (CNM-2020)។ ចាប់ពីឆ្នាំ២០១៣មករហូតមកដល់បច្ចុប្បន្ន កម្មវិធីផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន បានពង្រីកដល់សិស្សានុសិស្សមធ្យមសិក្សាថែមទៀត ដោយរៀបចំដំណាលគ្នានឹងយុទ្ធនាការផ្តល់វីតាមីនអា ដែលធ្វើនៅក្នុងខែវិច្ឆិកានិងខែឧសភា។

ទន្ទឹមគ្នានេះ សិស្សានុសិស្សភាគច្រើនមិនបានតាមដានសុខភាពរបស់ខ្លួននោះទេ ហើយការពិនិត្យសុខភាពប្រចាំឆ្នាំក៏មិនបានធ្វើទៀងទាត់លើកលែងតែមានជំងឺដែលត្រូវទៅពិនិត្យនិងព្យាបាល។ ហេតុដូចនេះ កុមារមានបញ្ហាខ្វះគីឡូ លើសគីឡូ បញ្ហាគំហើញ បញ្ហាកម្លាំងឮ ត្រូវបានរកឃើញចំពោះកុមារដែលស្ថិតក្នុងក្រុមគោលដៅបានពិនិត្យសុខភាពគាំទ្រដោយដៃគូ។ បញ្ហាកំហុសកំណុំរូបភាពភាគច្រើនភ្នែកមីញ៉ូបជាមូលហេតុចម្បង ដែលធ្វើឱ្យគំហើញចុះខ្សោយចំពោះកុមារអាយុចន្លោះ៥ទៅ១៥ឆ្នាំ។ ការសិក្សាមួយស្តីពីកំហុសសំណុំក្នុងចំណោមសិស្សដែលមានអាយុពី១២ទៅ១៤ឆ្នាំ កាលពីឆ្នាំ២០១០ ដោយកម្មវិធីជាតិសុខភាពភ្នែកនៃក្រសួងសុខាភិបាល បានបង្ហាញថា អត្រាប្រេវ៉ាឡង់នៃកំហុសសំណុំមាន១៣,៧ភាគរយ ចំពោះអ្នកនៅទីក្រុង និង២,៨ភាគរយចំពោះអ្នកនៅជនបទ ហើយអត្រានេះ អាចនឹងកើនឡើងនាពេលបច្ចុប្បន្នដោយសារការកើនឡើងនៃការប្រើប្រាស់បរិក្ខារឌីជីថល

មិនបានត្រឹមត្រូវ ក្នុងនោះភាគច្រើនគឺភ្នែកមីញ៉ូប។ ផលវិបាកធ្ងន់ធ្ងរនៃបញ្ហាកំហុសកំណុំរូបភាពលើកុមារគឺការវិវត្តទៅរកភ្នែកខ្ចិល ដែលជាប្រភេទភ្នែកមិនអាចមើលឆ្ងាយបានច្បាស់អស់មួយជីវិត បើទោះបីបានកែតម្រូវឬព្យាបាលដោយវ៉ែនតាក៏ដោយ។ ដូចគ្នានេះ បុគ្គលិកអប់រំភាគច្រើនក៏មិនសូវបានយកចិត្តទុកដាក់ក្នុងការពិនិត្យសុខភាពឬតាមដានសុខភាពប្រចាំឆ្នាំរបស់ខ្លួន ដែលប្រការនេះ ធ្វើឱ្យស្ថានភាពជំងឺមួយចំនួនហាក់ដូចជាធ្ងន់ធ្ងរពេលបានទៅជួបគ្រូពេទ្យពេលខ្លួនធ្លាក់ខ្លួនឈឺ ទន្ទឹមគ្នានឹងមានជំងឺថប់បារម្ភ ការធ្លាក់ទឹកចិត្ត និងការប៉ះទង្គិចផ្លូវចិត្តពិសេសបុគ្គលិកអប់រំដែលមានវ័យចាប់ពី៥០ឆ្នាំឡើងទៅ។ ដំណោះស្រាយដ៏ប្រសើរ គួរមានកម្មវិធីពិនិត្យសុខភាពអ្នកសិក្សានិងបុគ្គលិកអប់រំប្រចាំឆ្នាំ ដើម្បីងាយស្រួលក្នុងការអន្តរាគមន៍ទាន់ពេលវេលា និងមិនឈានទៅរកស្ថានភាពធ្ងន់ធ្ងរពិបាកព្យាបាលរហូតដល់បាត់បង់ជីវិតថែមទៀតផង។ ជាក់ស្តែងដូចជាស្ថានភាពនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ករណីរកឃើញភ្លាមៗនៃអ្នកមានជំងឺកូវីដ-១៩ និងទទួលការព្យាបាលភ្លាមៗអាចកាត់បន្ថយអាត្រាមរណភាពបានច្រើន ព្រមទាំងកាត់ផ្តាច់ការចម្លងទៅក្រុមគ្រួសារនិងសហគមន៍ផងដែរ។

មួយវិញទៀតតាមការអង្កេតជាសកល ស្តីពីការយល់ដឹងនិងឥរិយាបថប្រព្រឹត្តទាក់ទងផ្នែកសុខភាពរបស់សិស្សនៅកម្ពុជាក្នុងឆ្នាំ២០១៣ (GSHS-2013) បានបង្ហាញថា សិស្សមធ្យមសិក្សាចំនួន១១,៩ភាគរយ បានរាយការណ៍ថា ពួកគេធ្លាប់ឆ្លងកាត់ការរួមភេទ។ ទង្វើនេះភាគច្រើនគឺសិស្សប្រុសដែលមានចំនួនរហូតដល់ ១៤,៣ភាគរយ បើធៀបជាមួយសិស្សស្រីដែលមានចំនួន ៩,៤ភាគរយ។ ក្នុងចំណោមអ្នកធ្លាប់រួមភេទទាំងនេះ មានតែប្រមាណ៣០ភាគរយប៉ុណ្ណោះដែលសារភាពថាជានិច្ចជាកាលបានប្រើស្រោមអនាម័យ ហើយ១៦ភាគរយ ឆ្លើយថាបានរួមភេទនៅពេលពួកគេស្រវឹង។ ការសិក្សានេះក៏បានបង្ហាញដែរថាសិស្សមធ្យមសិក្សាចំនួន៥,៧ភាគរយ តែងតែមានអារម្មណ៍ថាមានភាពឯកាស្ទើរតែជារៀងរាល់ថ្ងៃ។ សិស្សប្រមាណចន្លោះពី៣ទៅ៦ភាគរយ មានការព្រួយបារម្ភរហូតដល់មិនឃ្លានអាហារឬមិនអាចញ៉ាំអាហារបាន ឬរហូតដល់មិនអាចគេងបាន។ ជិតពាក់កណ្តាលនៃសិស្សដែលមានការថប់បារម្ភទាំងនោះ មូលហេតុដោយសារមានគេសម្លុត គម្រាម ប្រមាថជាដើម។ សិស្សប្រមាណជា ៨,៨ភាគរយ បានរៀបគម្រោងលើការធ្វើអត្តឃាត រីឯសិស្សចំនួន ៦,៨ភាគរយ បានធ្លាប់ធ្វើអត្តឃាតយ៉ាងតិចមួយលើករួចមកហើយ។ តាមរយៈទិន្នន័យនេះ បង្ហាញពីកិច្ចការមួយចំនួនដែលគួរត្រូវបានរៀបចំឆ្លើយតបដូចជាការពង្រីកសេវាផ្តល់ប្រឹក្សាសុខភាពផ្លូវចិត្តបឋម និងសេវាមេត្រីភាពយុវវ័យទាក់ទងនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជដល់សិស្សានុសិស្សចាប់ពីកម្រិតមធ្យមសិក្សាឡើងទៅ។

ការរៀបចំឱ្យមានបន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅ ទើបតែចាប់ផ្តើមក្នុងសញ្ញាល្អមួយគឺគិតត្រឹមឆ្នាំ២០២០ គ្រឹះស្ថានចំណេះទូទៅចំនួន២៥០កន្លែង បានផ្តួចផ្តើមរៀបចំឱ្យមានបន្ទប់សុខភាពសម្រាប់ផ្តល់សេវាសង្គ្រោះបឋម ផ្តល់ប្រឹក្សា ពិនិត្យសុខភាព និងជាកន្លែងផ្តល់ព័ត៌មានពីសេវាព្យាបាលនិងថែទាំសុខភាពផ្សេងៗដល់បុគ្គលិកអប់រំនិងអ្នកសិក្សា។ ចំណែកនៅតាមគ្រឹះស្ថានឧត្តមសិក្សាមួយចំនួនក៏ចាប់ផ្តើមដាក់ឱ្យដំណើរការបន្ទប់សុខភាពរបស់ខ្លួនផងដែរ។ តែទោះ

ជាយ៉ាងណាក៏ដោយបន្ទប់សុខភាពទាំងនោះមិនទាន់បានរៀបចំឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយសមតាមលក្ខណៈបច្ចេកទេស និងតម្រូវការជាក់ស្តែងនៅឡើយ ទាំងសម្ភារៈប្រើប្រាស់ ទាំងការរៀបចំនិងការប្រព្រឹត្តទៅនៃបន្ទប់សុខភាព ព្រមទាំងកង្វះខាងមន្ត្រីជំនាញដែលបម្រើការនៅតាមបន្ទប់សុខភាពទាំងនោះផងដែរ។ លើសពីនេះទៀត ការរៀបចំឱ្យមានសម្ភារៈសង្គ្រោះបឋមនៅតាមគ្រឹះស្ថានសិក្សាក៏នៅជួបបញ្ហាប្រឈមផងដែរ ដោយនៅឆ្នាំ២០២០ គ្រឹះស្ថានសាធារណៈចំនួនតែ ៥១,៤ភាគរយប៉ុណ្ណោះដែលមានសម្ភារៈ សង្គ្រោះបឋមប្រើប្រាស់បាន ក្នុងនោះបឋមមត្តេយ្យសិក្សាដាច់ដោយឡែកមានតែ៣២,៤ភាគរយ បឋមសិក្សាមាន ៥៣,៥ភាគរយ អនុវិទ្យាល័យមាន៣៨,៣ភាគរយ និងវិទ្យាល័យមាន ៦១,៤ភាគរយ។ ដោយឡែកគ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមិនមានទិន្នន័យបង្ហាញច្បាស់លាស់នោះទេ តែទោះជាយ៉ាងក៏ឃើញមានគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយចំនួនបានផ្ញើរបាយការណ៍ជាទៀងទាត់ពាក់ព័ន្ធនឹងការផ្តល់សេវាពិនិត្យសុខភាពនិងការសង្គ្រោះបឋមដល់និស្សិតមកក្រសួងអប់រំ យុវជន និងកីឡាផងដែរ។

ទន្ទឹមគ្នានឹងជំងឺឆ្លង ប្រជាជនកម្ពុជាក៏ប្រឈមនឹងជំងឺមិនឆ្លងផងដែរ។ អត្រាស្លាប់នៃជំងឺមិនឆ្លងបានកើនឡើងជារៀងរាល់ឆ្នាំ ហើយកើនដល់៦៤ភាគរយ នៃអត្រាស្លាប់សរុបគិតត្រឹមឆ្នាំ២០១៨ ក្នុងនោះជិត៦០ភាគរយបណ្តាលមកពីជំងឺសរសៃឈាមបេះដូង ជំងឺទឹកនោមផ្អែម និងមហារីក។ ជំងឺមិនឆ្លងជាជំងឺរ៉ាំរ៉ៃ បណ្តាលឱ្យមានពិការភាព បាត់បង់ពលកម្ម និងកំពុងតែគំរាមកំហែងដល់ភាពក្រីក្រ និងបង្កឱ្យមានការចំណាយយ៉ាងច្រើនទៅលើការថែទាំសុខភាព។ ប៉ុន្តែវិធានការសម្រាប់ការការពារ និងការប្រយុទ្ធនឹងជំងឺមិនឆ្លងដ៏មានប្រសិទ្ធភាព ដែលត្រូវអនុវត្ត ព្រោះថា៨០ភាគរយនៃជំងឺមិនឆ្លងអាចបង្ការបានដោយគ្រាន់តែដោះស្រាយកត្តាប្រឈមចំនួន៤ គឺ៖ ការប្រើប្រាស់ថ្នាំជក់ ការប្រើប្រាស់គ្រឿងស្រវឹងប្រកបដោយគ្រោះថ្នាក់ របបអាហារដែលគ្មានសុខុមាលភាព និងកង្វះកាយវប្បកម្ម។ នៅប្រទេសកម្ពុជា មានសិស្សប្រមាណជា៣ភាគរយ បានជក់បារីឬប្រើប្រភេទថ្នាំជក់ផ្សេងៗយ៉ាងតិចមួយថ្ងៃ ក្នុងកំឡុងពេល៣០ថ្ងៃកន្លងទៅ។ ក្នុងចំណោមអ្នកដែលជក់បារីទាំងអស់នោះ មានសិស្សប្រមាណជា ៤៨,៣ភាគរយ បានសាកល្បងជក់នៅមុនអាយុ១៤ឆ្នាំ (GSHS-2013)។ ជំងឺមិនឆ្លងមិនត្រឹមតែជាបញ្ហាសុខភាពតែមួយប៉ុណ្ណោះទេ ប៉ុន្តែវាជាបញ្ហាប្រឈមមួយចំពោះការអភិវឌ្ឍផងដែរ ដែលគំរាមកំហែងដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ព្រមទាំងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននិងសង្គមទាំងមូល។ ការខាតបង់ផ្នែកសេដ្ឋកិច្ចទាំងការចំណាយដោយផ្ទាល់និងប្រយោល ដោយសារតែជំងឺមិនឆ្លងមានចំនួន៥,៩៧ទ្រីលានរៀល ដែលស្មើនឹង៦,៦ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ២០១៨។ ការកើនឡើងនៃជំងឺមិនឆ្លងនៅប្រទេសកម្ពុជាមិនអាចដោះស្រាយបានដោយក្រសួងសុខាភិបាលតែមួយនោះទេ។ មូលហេតុចម្បងជាច្រើននិងកត្តាកំណត់សុខភាពនៃជំងឺមិនឆ្លងស្ថិតនៅក្រៅវិស័យសុខាភិបាល ដូចជាកត្តាចំណីអាហារ និងបរិស្ថានដែលយើងរស់នៅ។

**កង្វះអាហារូបត្ថម្ភ**នៅតែជាបញ្ហាចម្បងមួយនៅប្រទេសកម្ពុជា បើទោះបីជាមានការកែលម្អជាច្រើនឆ្នាំដំបូងនៃទសវត្សរ៍ចុងក្រោយនេះក៏ដោយ។ តាមរបាយការណ៍អង្កេត ស្តីពីសុខភាពនិងប្រជា

សាស្ត្រឆ្នាំ២០២១-២០២២ (CDHS 2021-2022) បានបង្ហាញថា ស្ថានភាពអាហារូបត្ថម្ភរបស់កុមារកម្ពុជាអាយុក្រោម៥ឆ្នាំមានបម្រែបម្រួលខ្លាំងនូវអត្រាប្រេវ៉ាឡង់នៃភាពក្រិនក្រិស ដោយបានថយចុះពី៣២ភាគរយក្នុងឆ្នាំ២០១៤ មកនៅត្រឹម២២ភាគរយ ក្នុងឆ្នាំ២០២១-២០២២។ ភាពស្គមស្គាំងរបស់កុមារបានថយចុះតិចតួចពី១១ភាគរយក្នុងឆ្នាំ២០១០ មកនៅ១០ភាគរយក្នុងឆ្នាំ២០១៤ និងបន្តនៅថេរ១០ភាគរយនៅឆ្នាំ២០២១-២០២២។ ដោយឡែកកុមារលើសទម្ងន់មានការកើនឡើងគួរឱ្យកត់សម្គាល់ពី២ភាគរយក្នុងឆ្នាំ២០១៤ ដល់៤ភាគរយក្នុងឆ្នាំ២០២១-២០២២។ ទន្ទឹមនឹងនេះ តាមការសិក្សារបស់អង្គការ FIDR នៅឆ្នាំ២០១៥ បានបង្ហាញថា កុមារក្នុងវ័យសិក្សា ពីអាយុ ៦ឆ្នាំដល់ ១៧ឆ្នាំនៅតាមគ្រឹះស្ថានសិក្សានៃតំបន់ជនបទ មានសភាពក្រិន ៣៦ភាគរយ ស្គមស្គាំង ១៦ភាគរយ និងទម្ងន់ទាបជាងស្តង់ដា ៣៨ភាគរយ។ ប្រេវ៉ាឡង់នៃសិស្សខ្វះអាហារូបត្ថម្ភក្នុងចំណោមកុមារក្នុងវ័យសិក្សាត្រូវបានប៉ាន់ប្រមាណថានៅតែខ្ពស់ឬធ្ងន់ធ្ងរប្រើប្រៀបធៀបនឹងកុមារអាយុក្រោម៥ឆ្នាំ។

តាមការអង្កេតជាសកល ស្តីពីការយល់ដឹងនិងឥរិយាបថប្រព្រឹត្តទាក់ទងផ្នែកសុខភាពរបស់សិស្សនៅកម្ពុជា (GSHS) ក្នុងឆ្នាំ២០១៣ បានបង្ហាញថាសិស្សនៅតាមសាលាមធ្យមសិក្សាមានទម្ងន់មិនគ្រប់គីឡូ(គីឡូតិច) ដែលមានចំនួនប្រមាណជាបីដងច្រើនជាងសិស្សដែលមានទម្ងន់លើសគីឡូ និងប្រមាណជាដប់ដងបើធៀបនឹងអ្នកដែលមានរោគធាត់។ មានសិស្សម្នាក់ក្នុងចំណោមប្រាំនាក់បានញ៉ាំផ្លែឈើស្រស់ ក្នុងរយៈពេល៣០ថ្ងៃចុងក្រោយ ហើយមានតែ១២ភាគរយ ដែលញ៉ាំផ្លែឈើស្រស់រៀងរាល់ថ្ងៃ។ ផ្ទុយទៅវិញមានសិស្សម្នាក់ក្នុងចំណោមសិស្សពីរនាក់បានញ៉ាំភេសជ្ជៈផ្អែមយ៉ាងតិចម្តងក្នុងមួយថ្ងៃក្នុងកំឡុងពេល៣០ថ្ងៃកន្លងទៅ។

តាមរយៈរបាយការណ៍សមិទ្ធផលសុខាភិបាលប្រចាំឆ្នាំ បានបង្ហាញថាជំងឺរាកមានអត្រាប្រេវ៉ាឡង់ខ្ពស់ នៅក្នុងចំណោមជំងឺចម្បងៗចំនួន១០ ដែលកើតលើកុមារនិងមនុស្សទូទៅ មានប្រមាណចំនួនកន្លះលាននាក់ ជារៀងរាល់ឆ្នាំក្នុងរយៈពេលច្រើនឆ្នាំចុងក្រោយនេះ។ បញ្ហាកង្វះអាហារូបត្ថម្ភ ធ្វើឱ្យជំងឺរាកកាន់តែកើតឡើងញឹកញាប់និងអូសបន្លាយយូរជាងមុន។ យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ បានបង្ហាញថា នៅតាមតំបន់ជនបទ ប្រជាជន៧៨,៣ភាគរយដែលមានបង្គន់ប្រើប្រាស់ ៧៨,៦ភាគរយ មានទឹកស្អាតប្រើប្រាស់។ នៅពេលមានបញ្ហាកង្វះអនាម័យ និងការផ្គត់ផ្គង់ទឹកស្អាត ប្រជាជនកម្ពុជាតែងតែប្រឈមនឹងឆ្លងដែលអាចបង្កឱ្យមានជំងឺកាន់តែច្រើននៅក្នុងបរិស្ថានជុំវិញ។ កុមារដែលមានជំងឺដោយសារការទទួលទានទឹកមិនស្អាត និងកង្វះអនាម័យនឹងមានបញ្ហាខ្សោយពោះវៀន ដែលធ្វើឱ្យពិបាកក្នុងការស្រូបបឺតយកសារជាតិចិញ្ចឹមនានា។ កុមារក្រិន រៀនមិនពូកែឡើយ ដោយសារតែពួកគេ ទទួលបានការខូចខាតប្រព័ន្ធសម្រាប់ស្រូបយកចំណេះដឹងនៅក្នុងរយៈពេលវែង។

ការលើកកម្ពស់អាហារូបត្ថម្ភនៅតាមគ្រឹះស្ថានសិក្សា ត្រូវបានអនុវត្តជាជំហានៗ ជាពិសេសការផ្តល់អាហារពេលព្រឹកនៅតាមសាលាបឋមសិក្សាតាមរយៈអង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) ដែលស្ថិតនៅក្នុងសហគមន៍មានអសន្តិសុខស្បៀង បានអនុវត្តចាប់តាំងពីឆ្នាំ១៩៩៩ ដោយ

កុមារជិតកន្លះលាននាក់នៅតាមបណ្តារាជធានី ខេត្តបានទទួលផលពីកម្មវិធីនេះក្នុងរយៈពេលជាង ១០ឆ្នាំដំបូង។ តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះ កម្មវិធីអាហារូបត្ថម្ភបានធ្វើពិពិធកម្មតាមស្ថានភាពរបស់គ្រឹះស្ថានសិក្សានីមួយៗវិញ ជាក់ស្តែងនៅឆ្នាំសិក្សា២០១៩-២០២០ ការផ្តល់ស្បៀងអាហារតាមសាលារៀនបាន ១ ១៦៧សាលា មានសិស្សចំនួន៣២៥ ៩៥៧នាក់ ស្រី៤៩ភាគរយ ក្នុងនោះការផ្តល់អាហារពេលព្រឹកដោយប្រើប្រាស់ កសិផលសហគមន៍ ២៦៧សាលា មានសិស្ស ៥៦ ៧៨៥នាក់ ស្រី៤៩ភាគរយ នៅខេត្តបាត់ដំបង កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ធំ ស្ទឹងត្រែង សៀមរាប ឧត្តរមានជ័យ និងព្រះវិហារ សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក។ លើសពីនេះ មានការផ្តល់អាហារូបករណ៍ដល់សិស្សចំនួន ១១០ ១៥៦នាក់ ស្រី៥៤ភាគរយ ក្នុងនោះសិស្សថ្នាក់ទី១ ដល់ថ្នាក់ទី៣ មាន ៥ ០០០នាក់ ស្រី ៥៤,២ភាគរយ មកពី ៤ ៩៥១ សាលា ១៨៤ ក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្ត និងកម្មវិធីស្បៀងអាហារពិភពលោក ផ្តល់អាហារូបករណ៍ជាស្បៀងចំនួន ៨ ៤១៤នាក់ ស្រី៥៦ភាគរយ មកពី៤៤៣សាលា។

គ្រឹះស្ថានសិក្សានៅប្រទេសកម្ពុជាភាគច្រើននៅតំបន់ទីប្រជុំជនមានការលក់ដូរចំណីអាហារដើម្បីបម្រើដល់សេចក្តីត្រូវការរបស់បុគ្គលិកអប់រំនិងអ្នកសិក្សា ពិសេសអ្នកដែលគ្មានពេលចម្អិនអាហារពីផ្ទះមកទទួលទាននៅតាមគ្រឹះស្ថានសិក្សា។ កន្លែងលក់ដូរ ឬអាហារដ្ឋាននៅតាមគ្រឹះស្ថានសិក្សាមិនទាន់ធានាបាននូវសុវត្ថិភាពក្នុងការទទួលទាន ហើយចំណីអាហារទៀតសោតនៅមិនទាន់មានប្រព័ន្ធត្រួតពិនិត្យជាប្រចាំនិងគ្មានការធានាតាមស្តង់ដាជាតិម្ហូបអាហារនៅឡើយ។ គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនចាប់ពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សាមួយចំនួនធំ មិនទាន់បានរៀបចំជាស្តង់ដាកន្លែងលក់ដូរ ឬកន្លែងទទួលទានចំណីអាហារឱ្យមានភាពទាក់ទាញ អនាម័យ ល្អ មានសុវត្ថិភាព និងមិនសមរម្យជាកន្លែងទទួលទាន ហើយការគ្រប់គ្រងកាកសំណល់ផ្ទះបាយ ក៏មិនទាន់សមតាមលក្ខណៈបច្ចេកទេសនៅឡើយ។ ជាមួយគ្នានេះ ការលក់ដូរភេសជ្ជៈប៉ូវកម្លាំង ភេសជ្ជៈផ្អែមខ្លាំង ប្រៃខ្លាំង អាហារមានខ្លាញ់ច្រើន ចំណីអាហារវេចខ្ចប់ដែលគ្មានសញ្ញាសម្គាល់ច្បាស់លាស់ ឬគ្មានកាលបរិច្ឆេទកំណត់ប្រើប្រាស់ត្រឹមត្រូវ នៅតែមានវត្តមាននៅតាមគ្រឹះស្ថានសិក្សា។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ការពុលចំណីអាហារ ការថប់បារម្ភ និងឈានទៅដួលសន្លប់ នៅតាមគ្រឹះស្ថានសិក្សាមានការកើនឡើងគួរឱ្យបារម្ភ។ ដោយឡែកការពុលអាហារនៅតាមសហគមន៍ ក៏មានជាហូរហែរ ហើយករណីខ្លះអាចឈានដល់ស្លាប់ក៏មាន ពិសេសករណីពុលស្រា។

ទន្ទឹមនឹងកម្មវិធីខាងលើ បញ្ហាសុវត្ថិភាពនិងសុខុមាលភាពចំណីអាហារត្រូវបានរៀបចំជាបណ្តើរៗផងដែរ ជាក់ស្តែងក្រសួងអប់រំ យុវជន និងកីឡា បានចេញសេក្តីណែនាំជាបន្តបន្ទាប់ដូចជាការលើកកម្ពស់សុវត្ថិភាពនិងសុខុមាលភាពចំណីអាហារ ការហាមឃាត់ការប្រើប្រាស់ផលិតផលថ្នាំជក់និងគ្រឿងស្រវឹងជាដើម។ ជាមួយគ្នានេះដែរ សមត្ថភាពអ្នកចម្អិនអាហារនៅតាមគ្រឹះស្ថានសិក្សាដែលមានការអនុវត្តកម្មវិធីស្បៀងអាហារពេលព្រឹក ក៏ត្រូវបានពង្រឹងតាមរយៈការចុះអប់រំផ្ទាល់ពីមន្ត្រីជំនាញពីកូនសោគន្លឹះទាំងប្រាំនៃការរៀបចំចំណីអាហារប្រកបដោយសុវត្ថិភាពរបស់អង្គការសុខភាពពិភព

លោក ព្រមទាំងមានការលើកទឹកចិត្តអ្នកចម្អិនអាហារទាំងនោះ តាមរយៈចលនាប្រឡងប្រណាំងអ្នកចម្អិនអាហារឆ្នើមប្រចាំឆ្នាំជាដើម។ ការលើកកម្ពស់សួនបន្លែនិងសួនជីវៈចម្រុះនៅតាមគ្រឹះស្ថានសិក្សាបាននិងកំពុងអនុវត្តជាបន្តបន្ទាប់នៅតាមគ្រឹះស្ថានសិក្សា ហើយការដាំដុះបន្លែនិងរុក្ខជាតិដែលស៊ាំនឹងបម្រែបម្រួលអាកាសធាតុក៏ត្រូវបានលើកទឹកចិត្តដោយមានជំនួយបច្ចេកទេសពីក្រសួងនិងដៃគូពាក់ព័ន្ធ បើទោះបីជាការងារនេះនៅមានទ្រង់ទ្រាយតូចក៏ដោយ។

**ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ**នៅតាមគ្រឹះស្ថានសិក្សាត្រូវបានរាជរដ្ឋាភិបាលកម្ពុជា បានរៀបចំជាជំហានៗទៅតាមដំណាក់កាលនីមួយៗតាមរយៈគោលនយោបាយជាតិស្តីពីទឹកស្អាតនិងអនាម័យអនុម័តឆ្នាំ២០០៣ ដោយកំណត់នូវទស្សនវិស័យច្បាស់លាស់ថា "នៅឆ្នាំ២០២៥ ប្រជាជនគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព"។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រជាតិដំណាក់កាលទី២ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់ការសម្អាតនិងអនាម័យនៅជនបទឆ្នាំ២០១៤-២០២៥ ក្នុងគោលបំណងធ្វើឱ្យសេវាទឹកស្អាត និងអនាម័យជនបទមានភាពប្រសើរឡើងនិងប្រកបដោយនិរន្តរភាព ក្នុងការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ ត្រូវបានដាក់ចេញដោយទទួលស្គាល់ការចូលរួមជាពហុវិស័យ និងជាឈ្នាន់ក្នុងការឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។

កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចូលសកម្មភាពការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យទៅក្នុងផែនការយុទ្ធសាស្ត្រអប់រំជាបន្តបន្ទាប់និងកំណត់សូចនាករសម្រាប់វាស់វែងវឌ្ឍនភាពប្រចាំឆ្នាំ ដើម្បីឆ្ពោះទៅសម្រេចបាន១០០ភាគរយ ត្រឹមឆ្នាំ២០២៥ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដើម្បីឱ្យការងារនេះសម្រេចបានជាជំហានៗតាមគោលដៅគ្រោងទុក នៅចុងឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញ "គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យតាមសាលារៀន" សម្រាប់ណែនាំដល់បុគ្គលិកអប់រំថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធឱ្យចូលរួមអនុវត្តជាជំហានៗ ដើម្បីធ្វើឱ្យស្ថានភាពទឹកស្អាត និងអនាម័យតាមសាលារៀន ឆ្លើយតបបានតាមតម្រូវការជាមូលដ្ឋានរបស់បុគ្គលិកអប់រំ និងអ្នកសិក្សា ក្នុងបំណងកាត់បន្ថយអត្រាឆ្លងជំងឺផ្សេងៗ ពិសេសជំងឺរាក និងជំងឺលោកផ្លូវដង្ហើម ព្រមទាំងកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភផងដែរ។

ចាប់តាំងពីឆ្នាំ២០១៦រហូតដល់ឆ្នាំ២០២០នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់កញ្ចប់ថវិកាដល់គ្រឹះស្ថានសិក្សាដែលមិនទាន់មានបង្គន់អនាម័យនិងបណ្តាញទឹកស្អាត ដើម្បីសាងសង់បង្គន់អនាម័យនិងបណ្តាញទឹកស្អាតសរុបចំនួន១ ២៥២កន្លែង ដោយគិតជាមធ្យម២៥០កន្លែងជារៀងរាល់ឆ្នាំ។ លើសពីនេះ ក៏មានការចូលរួមពីដៃគូអភិវឌ្ឍ សង្គមស៊ីវិល សហគមន៍ និងវិស័យឯកជន ក៏បានចូលរួមផ្តល់បន្ថែម រួមទាំងឧបករណ៍ចម្រោះទឹកស្អាត បរិក្ខារអនាម័យ ឡដុតសំរាម សាប៊ូលាងសម្អាត

ដៃ ថ្នាំដុសធ្មេញសម្រាប់ការអនុវត្តនៅតាមគ្រឹះស្ថានសិក្សាគោលដៅមួយចំនួន ដើម្បីលើកកម្ពស់ពីសារសំខាន់នៃវិធានការអនាម័យជាប់ជាប្រចាំ។ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាចំនួន២៩៦៣ បានទទួលការបំប៉នពីការអនុវត្តគោលការណ៍ណែនាំលក្ខ ខណ្ឌអប្បបរមាស្តីពីទឹកស្អាតនិងអនាម័យនៅតាមសាលារៀន តាមរយៈការគាំទ្រពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។

តែទោះបីជាមានការខិតខំប្រឹងប្រែងជាពហុវិស័យដូចបានរៀបរាប់ខាងលើក៏ដោយ ស្ថានភាពទឹកស្អាត និងអនាម័យនៅតាមគ្រឹះស្ថានសិក្សា នៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋាននៅឡើយ។ គិតត្រឹមឆ្នាំសិក្សា២០១៩-២០២០ ក្នុងចំណោមគ្រឹះស្ថានសិក្សាសរុបចំនួន៩ ២៨៦កន្លែងនៅទូទាំងប្រទេស គ្រឹះស្ថានសិក្សាចំនួន ៨ ៣៣២ កន្លែង ស្មើនឹង ៨៩,៧ភាគរយ មានទឹកស្អាតសម្រាប់ទទួលទាន៩ ២១២កន្លែង ស្មើនឹង ៩៩,២ភាគរយ មានបង្គន់អនាម័យប្រើប្រាស់ ៦ ៦៥៨ កន្លែង ស្មើនឹង ៧១,៧ភាគរយមានបរិក្ខារលាងសម្អាតដៃ។ ដោយឡែកបើគិតពីចំណាត់ថ្នាក់គ្រឹះស្ថានសិក្សាតាមកម្រិត (ផ្កាយ) ដើម្បីឆ្លើយតបទៅតាមគោលការណ៍ណែនាំលក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាតនិងអនាម័យ គិតត្រឹមឆ្នាំសិក្សាដូចគ្នាខាងលើឃើញថា គ្រឹះស្ថានដែលមានចំណាត់ថ្នាក់កម្រិត១ (ផ្កាយ១) ឡើងទៅបានបង្ហាញថា សាលាមត្តេយ្យជាច់ដោយឡែក មានចំនួនតែ៥១,៧ភាគរយ ថយចុះចំនួន៩,៥ភាគរយ សាលាបឋមសិក្សាមានចំនួន៧៤,០ភាគរយ កើនឡើង៣,៩ភាគរយ អនុវិទ្យាល័យ មានចំនួន៦៨,៦ភាគរយ កើនឡើង៦,២ភាគរយ និងវិទ្យាល័យមានចំនួន៧៧,៦ភាគរយ មានការកើនឡើង២,២ភាគរយ បើប្រៀបធៀបនឹងឆ្នាំសិក្សា២០១៨-២០១៩។ លើសពីនេះ យើងសង្កេតឃើញមានការកើនឡើងគួរឱ្យកត់សម្គាល់នូវការគិតគូរបស់គ្រឹះស្ថានសិក្សាក្នុងការរៀបចំការគ្រប់គ្រងការមករដូវរបស់កុមារី ឬសិស្សស្រីពី១៥,៧ភាគរយ កាលពីឆ្នាំសិក្សា២០១៨-២០១៩ មក២៦,៧ ភាគរយ នៅឆ្នាំសិក្សា២០១៩-២០២០ ផងដែរ តែចំនួននេះ នៅតិចតួចណាស់បើប្រៀបធៀបទៅនឹងតម្រូវការជាមូលដ្ឋាន។

ជាមួយគ្នានេះ កង្វះខាតវិធានការគ្រប់គ្រងសំរាម ទឹកសម្អុយ និងកាកសំណល់គ្រោះថ្នាក់ដទៃទៀត នៅមិនទាន់បានគិតគូរគ្រប់ជ្រុងជ្រោយស្របតាមលក្ខណៈបច្ចេកទេសនៅឡើយ។ បើរាប់បញ្ចូលលក្ខខណ្ឌទឹកស្អាតសម្រាប់ទទួលទាន តម្រូវការបរិក្ខារសម្រាប់ជនពិការ ទឹកស្អាតសម្រាប់ប្រើប្រាស់ សាប៊ូ និងឧបករណ៍អនាម័យដទៃទៀតសម្រាប់បម្រើដល់ការបង្ការទុកជាមុននូវការរាតត្បាតជំងឺឆ្លងនានានៅតាមគ្រឹះស្ថានសិក្សា នោះតម្រូវការនៅមានទំហំធំថែមទៀត។

ប្រការខាងលើនេះក្រសួងអប់រំ យុវជន និងកីឡា គួរសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងស្ថាប័នដទៃទៀត ដើម្បីគាំទ្រដល់ការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៅតាមសាលារៀនដូចជា អណ្តូងទឹក អាងត្រងទឹកភ្លៀង ឬស្រះសហគមន៍ស្របតាមបទដ្ឋានលក្ខណៈបច្ចេកទេស និងតាមដានការត្រួតពិនិត្យគុណភាពទឹកដោយអនុលោមតាមគោលការណ៍ណែនាំជាតិស្តីពីគុណភាពទឹកផឹកជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

**ការលើកកម្ពស់បរិស្ថានគ្រឹះស្ថានសិក្សា** ត្រូវបានរាជរដ្ឋាភិបាលសហការជាមួយគ្រប់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធក្នុងការធ្វើឱ្យគ្រឹះស្ថានសិក្សាមានសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាពជាបណ្ដើរៗស្របតាមការរីកចម្រើនផ្នែកសេដ្ឋកិច្ចនិងសង្គម។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវសេចក្ដីណែនាំជាច្រើនដូចជា សេចក្ដីណែនាំស្ដីពីការហាមឃាត់ការប្រើប្រាស់ ការផ្សព្វផ្សាយពាណិជ្ជកម្ម និងការតាំងលក់និងប្រើប្រាស់ផលិតផលថ្នាំជក់ និងគ្រឿងស្រវឹងក្នុងបរិវេណគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន សេចក្ដីណែនាំស្ដីពីការលើកទឹកចិត្តនិងការជំរុញលើកកម្ពស់ការប្រតិបត្តិទឹកស្អាតនិងអនាម័យនៅតាមសាលារៀនជាដើម។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីប្រឡងប្រណាំងសាសារៀនស្អាត សាលារៀនបរិស្ថានស្អាត នាយកល្អ គ្រូល្អប្រចាំឆ្នាំចាប់តាំងពីឆ្នាំ២០១៥មកដល់បច្ចុប្បន្ននេះ ដូចមានចែងក្នុងប្រកាសលេខ៦៥៨អយក.ប្រក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងបរិស្ថាន។

ដោយឡែក ការប្រែប្រួលអាកាសធាតុបានបង្កនូវការគម្រាមកំហែងដែលកើនឡើងជាលំដាប់ដល់សុវត្ថិភាព សុខភាព និងលទ្ធភាពសិក្សារៀនសូត្ររបស់សិស្ស។ យោងតាមសន្ទស្សន៍ហានិភ័យអាកាសធាតុសកល (Global Climate Risk Index 2019) កម្ពុជាត្រូវបានចាត់ថ្នាក់ទី៨៤ ក្នុងចំណោម១៣០ប្រទេស ដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុដូចជា កំណើនកម្ដៅ ខ្យល់ព្យុះ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងរលកកម្ដៅ។ អ្នកវិទ្យាសាស្ត្របានរកឃើញថា ចាប់ពីសម័យបដិវត្តន៍ឧស្សាហកម្មមក សីតុណ្ហភាពផែនដីបានកើនប្រមាណ១អង្សាសេ ហើយបានបង្កផលប៉ះពាល់កាន់តែធ្ងន់ធ្ងរជាងមុន និងមានរយៈពេលយូរអង្វែង (IPCC 2018)។ នាពេលថ្មីៗនេះ អង្គការឧតុនិយមពិភពលោកបានប្រកាសថា ត្រឹមឆ្នាំ២០២៦សីតុណ្ហភាពពិភពលោកអាចកើន១,៥អង្សាសេថែមទៀតធៀបនឹងកម្រិតមុនសម័យឧស្សាហកម្ម។ ការព្យាករណ៍អាកាសធាតុតាមសេណារីយ៉ូដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ខ្ពស់បានបង្ហាញថា នៅប្រទេសកម្ពុជានឹងអាចមានកំណើនសីតុណ្ហភាពរហូតដល់៣,១អង្សាសេ ត្រឹមឆ្នាំ២០៩០ ដោយធៀបទៅនឹងសីតុណ្ហភាពឆ្នាំគោល១៩៨៦-២០០៥ (Cambodia Climate Risk Profile 2021)។

ដោយសារកំណើនកម្ដៅខ្លាំងនៅឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញគោលការណ៍ណែនាំដល់គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនទាំងអស់ឱ្យកែប្រែម៉ោងបង្រៀនបំពាក់កង្ហារ លើកកម្ពស់ការផ្គត់ផ្គង់ទឹកប្រើប្រាស់ក៏ដូចជាទឹកបរិភោគ បើកទ្វារបង្អួចឱ្យស្រឡះមានខ្យល់ចេញចូលល្អ ព្រមទាំងផ្ដល់ពេលវេលាឱ្យសិស្សចេញលេងគ្រប់គ្រាន់ ដើម្បីជួយកាត់បន្ថយផលប៉ះពាល់ដល់សុខភាពសិស្ស និងនិស្សិត។ ក្នុងរយៈពេលវែង ក្រសួងអប់រំ យុវជន និងកីឡាក៏មានផែនការស្ដារស្រះទឹកនៅតាមសាលារៀន និងណែនាំឱ្យដាំប្រភេទដើមឈើលូតលាស់លឿននៅក្នុងទីធ្លាសាលារៀនជាវិធានការមួយដែលអាចរួមចំណែកកាត់បន្ថយផលប៉ះពាល់ពីការឡើងកម្ដៅ។

នៅឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងបរិស្ថាន បានសហការផលិតឯកសារអប់រំស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់មធ្យមសិក្សាទុតិយភូមិ និងបានដាក់ឱ្យប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀន និងបង្រៀននៅតាមសាលារៀនមធ្យមសិក្សាចំណោះទូទៅ ក្នុងគោលបំណងបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ និងវិធានការឆ្លើយតបចាំបាច់នានា។

ដើម្បីលើកកម្ពស់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យអប់រំឱ្យកាន់តែល្អប្រសើរថែមទៀត ចាំបាច់គួរពិចារណាលើវិធានការជាយុទ្ធសាស្ត្រចំនួន៣គឺ ១) ការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ២) ការប្រមូលព័ត៌មានទាក់ទងនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុរបស់សាលារៀននិង ៣) ការចាត់វិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅតាមសាលារៀន និងសហគមន៍។

តែទោះបីមានការខិតខំយ៉ាងនេះ ក៏ដោយគ្រឹះស្ថានសិក្សាមួយចំនួននៅមិនទាន់ឆ្លើយតបបានទៅនឹងតម្រូវការអប្បបរមានៅឡើយ។ ជាក់ស្តែង នៅមានចន្លោះប្រហោងដែលត្រូវបំពេញដូចជា ត្រូវពង្រឹងបន្ថែមទៀតនូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធលម្អក្នុងនិងក្រៅបរិវេណគ្រឹះស្ថានសិក្សា ការដាំដើមឈើយកម្លប់ ការគ្រប់គ្រងសំរាមនិងកាកសំណល់ ការដាក់ស្លាកសញ្ញាហាមឃាត់ឬសញ្ញារម្លឹក ការបំពាក់ឧបករណ៍ពន្លត់អគ្គីភ័យ ឧបករណ៍ការពាររន្ទះបាញ់ និងសញ្ញាចរាចរណ៍ ដើម្បីបង្ការហានិភ័យគ្រោះថ្នាក់ជាយថាហេតុ និងការបង្ការជំងឺឆ្លងដល់បុគ្គលិកអប់រំ និងអ្នកសិក្សា។

**ការលើកកម្ពស់សន្តិសុខនិងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា** ក៏ស្ថិតនៅជាបញ្ហាប្រឈមក្នុងការដោះស្រាយចំពោះមុខផងដែរ ថ្វីត្បិតស្ទើរតែគ្រប់គ្រឹះស្ថានសិក្សាមានបទបញ្ជាផ្ទៃក្នុង មានការរៀបចំឱ្យមានក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន ព្រមទាំងរៀបចំឱ្យមានយុវជនកាកបាទក្រហម យុវជនកាយរឹទ្ធសម្រាប់គ្រឹះស្ថានសិក្សាក៏ដោយ ក៏ប្រសិទ្ធភាពនិងគុណភាពការងារនៅមិនទាន់ឆ្លើយតបទៅនឹងការលើកកម្ពស់សុខភាពនៅឡើយ។ គ្រឹះស្ថានសិក្សាមួយចំនួន ពិសេសនៅតាមទីជនបទគ្មានរបងនិងគ្មានការយាមកាមត្រឹមត្រូវ។ ផ្ទុយទៅវិញ គ្រឹះស្ថានសិក្សាមួយចំនួននៅតាមទីប្រជុំជន មានការរំខានដោយមាន ក្លិបកំសាន្តឬកន្លែងទទួលទានគ្រឿងស្រវឹងនៅកៀកឬជាប់ក្បែររបងតែម្តង ដែលបានទាក់ទាញសិស្សទៅប្រើប្រាស់សេវាទាំងនោះទាំងក្នុងពេលម៉ោងសិក្សា និងក្រៅម៉ោងសិក្សា។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ គ្រប់អ្នកពាក់ព័ន្ធត្រូវចូលរួមសហការធ្វើយ៉ាងណាអនុវត្តគោលការណ៍ "សាលារៀនមួយ តំបន់សុខសាន្តមួយ" ព្រមទាំងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការចេញអាជ្ញាបណ្ណបើកកន្លែងក្លិបកំសាន្ត ឱ្យឆ្ងាយពីសាលារៀន និងរួមគ្នាចូលរួមធានាសន្តិសុខ និងសុវត្ថិភាពបុគ្គលិកអប់រំនិងអ្នកសិក្សា។

សុវត្ថិភាពតាមដងផ្លូវនៅតែប្រឈមខ្ពស់ ជាក់ស្តែងអត្រាគ្រោះថ្នាក់ចរាចរណ៍មានចំនួនកើនឡើង គួរឱ្យព្រួយបារម្ភនៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ដោយមានមនុស្សស្លាប់៥ទៅ៦នាក់ក្នុងមួយថ្ងៃៗ ក្នុងនោះរួមមានបុគ្គលិកអប់រំនិងអ្នកសិក្សាផងដែរ។ គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍

ផ្លូវគោក និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានប្រកាសផ្សព្វផ្សាយរបាយការណ៍ថ្មីមួយ ស្តីពីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅកម្ពុជានិងការខាតបង់សេដ្ឋកិច្ចដោយប្រើប្រាស់ទិន្នន័យ ឆ្នាំ២០១៩ បានបង្ហាញថា គ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងគឺ៩៨ភាគរយ បណ្តាលមកពីកំហុសរបស់មនុស្ស ដែលជាអ្នកបើកបរ ហើយអ្នកបាត់បង់ជីវិត៣ភាគ៤ គឺជាអ្នកបើកទោចក្រយានយន្ត បន្ទាប់មកថ្មើរជើង អ្នកប្រើប្រាស់រថយន្តគ្រួសារ និងអ្នកប្រើប្រាស់យានយន្តដឹកទំនិញ។ របាយការណ៍ដដែលបង្ហាញថា គ្រោះថ្នាក់ចរាចរណ៍ កើតឡើងដោយសារ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន ការបើកបរល្បឿនលឿន ការមិនគោរពច្បាប់ចរាចរណ៍ និងការប្រើប្រាស់ទូរស័ព្ទពេលកំពុងបើកបរ។ ឆ្នាំ២០១៩ កម្ពុជាខាតបង់ថវិកាចំនួន ៤៦៦,៨លានដុល្លារអាមេរិក ដោយក្នុងចំណោមការខាតបង់សរុប ៨៨.៨ ភាគរយ គឺដោយសារការបាត់បង់ជីវិត និងការបាត់ប្រាក់ចំណូល ដែលជនរងគ្រោះអាចរកបានពេញមួយជីវិត។

អំពើហិង្សាលើកុមារក៏ជាផ្នែកមួយទៀតដែលគួរត្រូវបានយកចិត្តទុកដាក់បន្ថែមផងដែរ។ អំពើហិង្សាលើកុមារកើតឡើងនៅគ្រប់ទីកន្លែងមិនថានៅក្នុងគ្រួសារ សហគមន៍ សាលារៀន កន្លែងការងារ កន្លែងកំសាន្តរួមទាំងក្លិបកីឡា ក្លិបយុវជន និងកន្លែងសាសនាដោយមិនប្រកាន់ថា អ្នកមានឬអ្នកក្រឡើយ។ ទោះជាអំពើហិង្សាលើកុមារមានច្រើនក្តី ក៏ការយកចិត្តទុកដាក់គាំទ្រនិងរកដំណោះស្រាយពីអ្នកពាក់ព័ន្ធ លើបញ្ហានេះ នៅមានកម្រិតនៅឡើយ។ ក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជាដោយមានការគាំទ្រពីអង្គការ UNICEF ក្រសួងកិច្ចការនារីបានសម្របសម្រួលនិងដឹកនាំធ្វើអង្កេតស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា ដែលជាការសិក្សាមួយគ្រប់ជ្រុងជ្រោយទូទាំងប្រទេសបានផ្តល់ភស្តុតាងអំពីវិសាលភាព និងចរិកនៃអំពើហិង្សាផ្លូវភេទ ផ្លូវកាយ ផ្លូវចិត្ត និងការមិនអើពើដែលកុមារីស្ត្រីវ័យក្មេង កុមារា និងបុរសវ័យក្មេងបានជួបប្រទះ។ លទ្ធផលនៃអង្កេតនេះបានបង្ហាញថាអំពើអំពើហិង្សាលើកុមារបានកើតឡើងយ៉ាងទូលំទូលាយ ដោយកុមារជាច្រើនទទួលរងអំពើហិង្សាជាច្រើនទម្រង់ដូចជា អំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ខណៈពេលដែលពួកគេចម្រើនពេញវ័យឡើង។ អំពើហិង្សាតែងតែប្រព្រឹត្តដោយអ្នកដែលកុមារស្រឡាញ់ និងនៅកន្លែងដែលកុមារមានអារម្មណ៍ថាគួរតែមានសុវត្ថិភាព។ របាយការណ៍បានគូសបញ្ជាក់ដែរថា កុមារភាគច្រើនមិនដែលនិយាយជាមួយអ្នកណាម្នាក់អំពីបទពិសោធន៍ដែលពួកគេបានជួបប្រទះ ហើយក៏មិនបានស្វែងរកជំនួយដែរ ប៉ុន្តែនៅពេលដែលពួកគេស្វែងរកជំនួយ គេតែងជួបប្រទះនូវឧបសគ្គជាច្រើនក្នុងការទទួលបានកិច្ចគាំទ្រ។ បន្ថែមលើនេះ ផលវិបាកជាច្រើននៃអំពើហិង្សាកាលពីកុមារភាពក្នុងនោះរួមមាន ការចុះអន់ថយនៃការអភិវឌ្ឍផ្នែកសង្គម ស្មារតី និងសតិបញ្ញាពេញមួយជីវិត ព្រមទាំងមានទំនាក់ទំនងកាន់តែខ្ពស់ទៅនឹងបញ្ហាជំងឺនិងសុខភាពផ្លូវចិត្ត និងការប៉ុនប៉ងធ្វើអត្តឃាត។

ការសេពគ្រឿងស្រវឹងជាបញ្ហាប្រឈមនៃអំពើហិង្សានិងបង្កគ្រោះថ្នាក់ចរាចរណ៍ផងដែរ។ តាមការអង្កេតជាសកលស្តីពីការយល់ដឹងនិងឥរិយាបថប្រព្រឹត្តទាក់ទងផ្នែកសុខភាពរបស់សិស្សនៅកម្ពុជាក្នុងឆ្នាំ២០១៣ (GSHS 2013) បានបង្ហាញថា១០ភាគរយនៃយុវសិស្សនៅតាមសាលាមធ្យមសិក្សា

កំពុងប្រើគ្រឿងស្រវឹង (ផឹកយ៉ាងតិចមួយកែវ មួយថ្ងៃឬច្រើនជាងមួយថ្ងៃក្នុងរយៈពេល៣០ថ្ងៃកន្លងទៅ)។ ក្នុងចំណោមអ្នកទាំងនោះ គឺមាន១៩.៥ភាគរយ បានសាកល្បងប្រើគ្រឿងស្រវឹងនៅមុនអាយុ១៤ឆ្នាំ ក្នុងនោះ សិស្សប្រុសមានចំនួន៣ទៅ៤ដងច្រើនជាងសិស្សស្រី (១៥ភាគរយទល់នឹង ៤,៦ភាគរយ)។ មានសិស្សចំនួនជិត៣ភាគរយ នៃអ្នកដែលផឹកគ្រឿងស្រវឹងនោះ មានបញ្ហាជាមួយក្រុមគ្រួសារឬមិត្តភ័ក្ត្រដែលជួនកាលមិនបានទៅរៀនឬក៏រហូតដល់មានការវាយតប់គ្នាទៀតផង។ ការមើលឃើញជារៀងរាល់ថ្ងៃក៏អាចជាគំរូមិនល្អដល់ក្រុមយុវសិស្សទាំងនោះដែរ ដោយប្រមាណជាង៣ក់កណ្ដាលនៃសិស្សសេពគ្រឿងស្រវឹងបានរាយការណ៍ថា ឪពុកម្ដាយឬអាណាព្យាបាលរបស់ពួកគេបានប្រើគ្រឿងស្រវឹង ហើយពួកគេភាគច្រើនបានឃើញការផ្សព្វផ្សាយគ្រឿងស្រវឹងជារៀងរាល់ថ្ងៃ តាមប្រព័ន្ធផ្សព្វផ្សាយនានា។ លើសពីនេះ ការសិក្សានេះបានបង្ហាញថា សិស្សមធ្យមសិក្សានៅកម្ពុជាមានប្រមាណជា០,៨ភាគរយ ធ្លាប់ប្រើគ្រឿងញៀនប្រភេទអំហ្វេតាមីនឬមេតាអំហ្វេតាមីនយ៉ាងតិចម្ដងនាពេលកន្លងមក ក្នុងនោះមាន៤៦,២ភាគរយ បានធ្លាប់សាកល្បងប្រើមុនអាយុ១៤ឆ្នាំ។ បើទោះជាលទ្ធផលបានបង្ហាញមានចំនួនតិចក្ដី តែព័ត៌មាននេះអាចជាកត្តាមួយគួរឱ្យបារម្ភព្រោះថាគ្រឿងញៀនបានកំពុងជ្រៀតចូលក្នុងមជ្ឈដ្ឋានសាលារៀនហើយ។ ការសិក្សានេះក៏បានបញ្ជាក់ផងដែរថា សិស្សម្នាក់ក្នុងចំណោមសិស្សប្រាំនាក់ បានទទួលរងការវាយប្រហារ និងម្នាក់ក្នុងចំណោមដប់នាក់បានវាយតប់គ្នា យ៉ាងតិចម្ដងក្នុងកំឡុងពេល១២ខែកន្លងទៅ ។ សិស្សប្រុសប្រឈមនឹងការរងការវាយប្រហារច្រើនជាងសិស្សស្រី ជាពិសេសសិស្សដែលនៅតាមទីប្រជុំជន។ សិស្សប្រមាណ២០ភាគរយ បានរងរបួសយ៉ាងតិចម្ដងក្នុងកំឡុងពេល១២ខែកន្លងទៅ ហើយក្នុងចំណោមនោះ របួសដែលកើតមានច្រើនជាងគេ គឺបាក់ឆ្អឹងនិងភ្លាត់ឆ្អឹង ដែលក្នុងចំណោមនោះ ការរងរបួសដែលមូលហេតុបណ្ដាលពីគ្រោះថ្នាក់ចរាចរ គឺមានរហូតដល់ទៅ ៣៣,៧ភាគរយ។

ហេតុនេះ ក្រៅពីការផ្ដល់ការអប់រំសុខភាព ការរៀបចំយន្តការដាក់ស្ដែងនិងច្បាស់លាស់ជាការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ឥរិយាបថគ្រោះថ្នាក់នានារបស់បុគ្គលិកអប់រំនិងអ្នកសិក្សា មិនត្រឹមតែនៅតាមគ្រឹះស្ថានសិក្សា តែក៏អាចជួយបាននៅតាមសហគមន៍ដូចគ្នាដែរ។

**ការលើកកម្ពស់ការអប់រំសុខភាព** ជាវិធានការចាំបាច់និងត្រូវអនុវត្តយូរអង្វែង ដើម្បីធានាថាអ្នកសិក្សាទទួលបានព័ត៌មានត្រឹមត្រូវ និងទទួលយកទៅអនុវត្តប្រចាំថ្ងៃក្នុងការបង្ការជំងឺឆ្លង ជំងឺមិនឆ្លង ការបង្ការគ្រោះថ្នាក់នានា ការថែទាំសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត។ យោងតាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសឆ្នាំ២០១៦-២០២៥ ដែលបានដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ ការអប់រំសុខភាពបានឈានដល់ដំណាក់កាលថ្មីមួយ គឺប្រែក្លាយពីមុខវិជ្ជាដែលបញ្ជ្រាបទៅក្នុងមុខវិជ្ជា៣ក់ព័ន្ធមានសិក្សាសង្គម ជីវវិទ្យា និងសីលធម៌ពលរដ្ឋ ទៅជាមុខវិជ្ជាអប់រំសុខភាពដាច់ដោយឡែកដែលមានរយៈពេល១ម៉ោងក្នុង១សប្ដាហ៍ចាប់ពីថ្នាក់ទី១ដល់ទី១២។ មុខវិជ្ជាថ្មីនេះ គ្របដណ្ដប់លើសមាសភាពចំនួន៦រួមមាន ១. សុខភាពបឋម ២. សុខភាពផ្លូវចិត្ត ៣. សុខ

ភាពផ្លូវភេទនិងសុខភាពបន្តពូជ ៤. សុខភាពនិងជំនឿ ៥. សុខភាពនិងបរិស្ថាន និង៦. សុខភាពនិងសេដ្ឋកិច្ច។

ថ្វីត្បិតមិនទាន់អភិវឌ្ឍបាននូវសៀវភៅសិក្សាគោលគ្រប់ថ្នាក់ក៏ដោយ ក៏គិតមកទល់ឆ្នាំ២០២០នេះ ដោយមានការសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលពាក់ព័ន្ធ កម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំសុខភាពសម្រាប់ថ្នាក់ទី១ ដល់ទី១២ ត្រូវបានអភិវឌ្ឍនិងអនុម័តកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ និងស្តង់ដាកម្មវិធីសិក្សាមុខវិជ្ជាអប់រំសុខភាពសម្រាប់ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ ត្រូវបានអភិវឌ្ឍនិងអនុម័តនាថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩។ លើសពីនេះ សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាពសម្រាប់គ្រូនិងសិស្សថ្នាក់ទី១ ទី៤ ទី៧ និងទី១០ ត្រូវបានរៀបចំនិងដាក់ឱ្យប្រើប្រាស់សាកល្បងក្នុងទ្រង់ទ្រាយតូច នៅតាមសាលារៀនគោលដៅមួយចំនួនក្រោមការគាំទ្រពីដៃគូ។ ដើម្បីជំរុញឱ្យការអប់រំសុខភាពនៅតាមគ្រឹះស្ថានសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បានចេញលិខិតណែនាំលេខ៣៣ អយក សស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបន្តការអនុវត្តកម្មវិធីសិក្សាពីប្រធានបទអប់រំសុខភាពនៅតាមគ្រឹះស្ថានបឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ក្នុងនោះបានអនុញ្ញាតឱ្យប្រើប្រាស់នូវខ្លឹមសារមេរៀនដែលមានស្រាប់សម្រាប់បឋមសិក្សា និងមធ្យមសិក្សា ទាំងការបង្ការជំងឺឆ្លង ជំងឺមិនឆ្លង និងគ្រោះថ្នាក់ផ្សេងៗ មុនពេលមានសៀវភៅសិក្សាគោលថ្មីសម្រាប់គ្រប់ថ្នាក់នាពេលខាងមុខ។

ទោះជាយ៉ាងនេះក៏ដោយ ក្នុងការដាក់ឱ្យដំណើរមុខវិជ្ជាអប់រំសុខភាពនេះ ក្រៅពីសៀវភៅសិក្សាគោល ចាំបាច់ត្រូវមានការបំប៉នគ្រូ ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូឯកសទេសមុខវិជ្ជាអប់រំសុខភាពផងដែរ។ លើសពីនេះ កម្មវិធីបណ្តុះបណ្តាលគ្រូនៅតាមគ្រឹះស្ថាន បណ្តុះបណ្តាលគ្រូគ្រប់កម្រិត ត្រូវធ្វើការកែលម្អតម្រូវទៅតាមបរិបទថ្មីនៃកម្មវិធីសិក្សាលម្អិតចំណេះទូទៅនិងអប់រំបច្ចេកទេស ព្រមទាំងតម្រូវឱ្យមានការបំប៉នគ្រូឧទ្ទេសផងដែរ។ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូសម្រាប់បឋមសិក្សានិងអប់រំមូលដ្ឋាន បានបង្កើតជាកម្មវិធីសិក្សាលម្អិតចំនួន២ក្រេឌីតសម្រាប់ប្រធានបទអប់រំសុខភាព តែមិនទាន់បានរៀបចំអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់គ្រូឧទ្ទេស និងគរុសិស្សនៅឡើយ។ លើសពីនេះទៀតសោត ការជ្រើសរើសនិងបំប៉នសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពសម្រាប់គ្រឹះស្ថានមធ្យមសិក្សា ចាំបាច់ត្រូវរៀបចំឱ្យមានលក្ខណៈសមស្រប ពិសេសត្រូវមានគ្រូឯកទេសសុខភាពសិក្សាដែលចេញពីគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ឬពីវិទ្យាស្ថានជាតិអប់រំ ឬវិទ្យាស្ថានគរុកោសល្យ។ បន្ថែមលើមុខវិជ្ជាអប់រំសុខភាព ដើម្បីឱ្យការអប់រំសុខភាព ធ្វើឡើងឆ្លើយតបទៅនឹងការរាតត្បាតជំងឺឆ្លង ការបង្ការជំងឺមិនឆ្លង ការលើកកម្ពស់អាហារូបត្ថម្ភ ស្ថានភាពនៃការបម្រែបម្រួលអាកាសធាតុ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ រួមទាំងបញ្ហាសុខភាពសាធារណៈផ្សេងទៀត ដែលកំពុងកើតមាន ចាំបាច់ត្រូវមានការអភិវឌ្ឍឧបករណ៍អប់រំផ្សព្វផ្សាយបន្ថែមទៀត។

ដោយឡែកនៅតាមគ្រឹះស្ថានឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេសឬវិជ្ជាជីវៈនានា ទាំងសាធារណៈនិងឯកជនមួយចំនួន បានបង្កើតជាប្រព័ន្ធក្រេឌិតសម្រាប់ប្រធានបទអប់រំសុខភាពដល់និស្សិតរបស់ខ្លួនជាប្រព័ន្ធរៀបរយ ហើយក៏មានលក្ខណៈមិនរៀបរយដូចជាមានបង្កើតវគ្គអប់រំសុខភាពលើប្រធានបទផ្សេងៗដូចជា ការអប់រំបង្ការគ្រឿងញៀនខុសច្បាប់ សុខភាពផ្លូវភេទ សុខភាពបន្តពូជ ការបង្ការមេរោគអេដស៍ ជំងឺអេដស៍ ការបង្ការអំពើហិង្សា បង្ការគ្រោះថ្នាក់ចរាចរណ៍។ល។ ក្នុងទម្រង់ជាសិក្ខាសាលា ឬវគ្គស្រាវជ្រាវក្រៅថ្នាក់ជាដើម។ តែទោះជាយ៉ាងណា កម្មវិធីសិក្សាប្រធានបទអប់រំសុខភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅមិនទាន់បានរៀបចំធ្វើព្រមៗគ្នាជាប្រព័ន្ធក្រេឌីតច្បាស់លាស់នៅឡើយ ដែលបញ្ហានេះជាផ្នែកមួយដ៏សំខាន់ក្នុងការពង្រឹងគុណវុឌ្ឍិ ដោយផ្ដើមចេញពីកាយសម្បទានិងចិត្តសម្បទារបស់ធនធានមនុស្សជំនាន់ក្រោយប្រកបដោយសក្ដានុពលសម្រាប់សង្គមជាតិ។

**ការលើកកម្ពស់បំណិនសុខភាព** ជួបនូវបញ្ហាប្រឈមមួយចំនួន ពិសេសកង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តហាត់ប្រាណ អនាម័យ និងការយល់ដឹងរបស់បុគ្គលិកអប់រំនិងអ្នកសិក្សាទាក់ទងនឹងស្ថានភាពសុខភាពនិងអាហារូបត្ថម្ភនៅមានកម្រិត។ ថ្វីត្បិតក្រសួងបានកំណត់ម៉ោងអប់រំកាយនិងកីឡាចំនួន២ម៉ោងក្នុង១សប្ដាហ៍ចំពោះគ្រឹះស្ថានសិក្សាចំណេះទូទៅ តែការអនុវត្តនៅតាមគ្រឹះស្ថានសិក្សាមិនបានគ្រប់ជ្រុងជ្រោយនៅឡើយ ព្រោះក្រៅពីកង្វះទីធ្លាសមស្របសម្រាប់ធ្វើសកម្មភាព នៅមានបញ្ហាប្រឈមដូចជា កង្វះគ្រូបង្ហាត់ កង្វះសម្ភារៈ និងការចូលរួមផងដែរ។ តាមការសិក្សាកាលពីឆ្នាំ២០១៣ (GSHS-2013) បានឃើញថា សិស្សមធ្យមសិក្សាចំនួនជិត៧២ភាគរយ បានរៀនពីផលប្រយោជន៍នៃការធ្វើលំហាត់ប្រាណ ក៏ប៉ុន្តែមានសិស្សតែម្នាក់ទេក្នុងចំណោមសិស្សដប់នាក់ដែលបានធ្វើលំហាត់ប្រាណយ៉ាងតិច៦០នាទីក្នុងមួយថ្ងៃ យ៉ាងតិចប្រាំថ្ងៃ ក្នុងរយៈពេល ៧ថ្ងៃកន្លងទៅ។

គិតមកដល់ឆ្នាំសិក្សា២០១៩-២០២០នេះ គ្រឹះស្ថានសិក្សាកម្រិតមត្តេយ្យនិងបឋមសិក្សាចំនួនជាង ៥០០កន្លែង បានដាក់ឱ្យអនុវត្តការលាងសម្អាតដៃនិងដុសសម្អាតធ្មេញជាក្រុមប្រចាំថ្ងៃ។ ដោយឡែកសិស្សមធ្យមសិក្សាមិនមានកម្មវិធីដុសសម្អាតធ្មេញទេ តែទោះជាយ៉ាងណាអត្រាប្រេវ៉ាឡង់នៃសិស្សមធ្យមសិក្សាដែលបានដុសសម្អាតធ្មេញតិចជាងមួយដងក្នុងមួយថ្ងៃ ក្នុងកំឡុងពេល៣០ថ្ងៃកន្លងទៅ មានចំនួនតែ៤ភាគរយ។ កត្តាទាំងនេះធ្វើឱ្យពួកគេចំនួនពីរនាក់ក្នុងចំណោមដប់នាក់ មានបញ្ហាធ្មេញរហូតដល់មិនបានទៅសាលារៀន ហើយសិស្ស ៣,៥ភាគរយ មានបញ្ហាមាត់ធ្មេញស្ទើរតែជាប្រចាំ។ ប្រមាណជា៦០ភាគរយនៃពួកសិស្សទាំងនោះ មិនដែលជួបជាមួយគ្រូពេទ្យធ្មេញ ដើម្បីធ្វើការពិនិត្យឬព្យាបាលឡើយ។ មួយវិញទៀត អត្រាសិស្សមធ្យមសិក្សាដែលមិនបានលាងសម្អាតដៃមុនពេលញ៉ាំអាហារ គឺមានចំនួនប្រមាណជិត២ភាគរយ។ សិស្សប្រមាណជា ២,៧ភាគរយ មិនបានលាងសម្អាតដៃក្រោយពេលចេញពីបង្គន់និងមិនបានឬកម្រប្រើសាប៊ូពេលលាងសម្អាតដៃ (GSHS-2013)។

ជាមួយគ្នានេះ ការញែកសំរាមតាមប្រភេទ ក៏បាននិងកំពុងអនុវត្ត ដែលជាផ្នែកមួយនៃការអនុវត្តតាមគោលការណ៍ណែនាំអប្បបរមា ស្ដីពីទឹកស្អាតនិងអនាម័យតាមសាលារៀន។ ការបំពាក់នូវ

ដញ្ជីងថ្លឹងទម្ងន់និងម៉ែត្រវាស់កម្ពស់ ក៏បានរៀបចំជាជំហានៗទៅតាមធនធានរបស់គ្រឹះស្ថានសិក្សា ហើយក៏បានជំរុញការអនុវត្តដើម្បីឱ្យអ្នកសិក្សាដឹងពីស្ថានភាពអាហារូបត្ថម្ភរបស់ខ្លួន។ ការអនុវត្តវិធានការបង្ការ ការរាតត្បាតនៃជំងឺឆ្លងនានាបាននិងកំពុងអនុវត្តនៅតាមគ្រឹះស្ថានសិក្សាទូទាំងប្រទេស ពិសេសក្នុងបរិបទជំងឺកូវីដ១៩។ គ្រឹះស្ថានសិក្សាមួយភាគធំនៅតាមទីប្រជុំជនបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តនូវវិធានការវាស់កម្តៅ ការពាក់ម៉ាស់ ការរក្សាគម្លាតសុវត្ថិភាព ការលាងសម្អាតដៃជាមួយទឹកស្អាតនិងសាប៊ូ ឬការលាងសម្អាតដៃជាមួយទឹកអាល់កុល ឬអាល់កុលជែល។ វិធានការនេះចាំបាច់ត្រូវពង្រឹងឱ្យបានម៉ឺងម៉ាត់បន្ថែមទៀតដើម្បីធានាបាននូវសុវត្ថិភាពដល់បុគ្គលិកអប់រំ និងអ្នកសិក្សា ក្នុងបរិបទនៃការរាតត្បាតជំងឺឆ្លងនានា។

**ការចូលរួមពីអ្នកពាក់ព័ន្ធ**ក្នុងការងារសុខភាពសិក្សា បានចាប់ដំណើរការជាបណ្តើរៗនៅតាមគ្រឹះស្ថានសិក្សាមួយចំនួនដោយសហការជាមួយវត្តអារាម សង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជនផងដែរបន្ថែមលើការជួយជ្រោមជ្រែងពីរាជរដ្ឋាភិបាល។ តែទោះជាយ៉ាងនេះក្តី ក៏ការងារសុខភាពសិក្សានៅមិនទាន់មានយន្តការឯកភាព ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់នានារបស់គ្រឹះស្ថានសិក្សានៅឡើយ។ កង្វះព័ត៌មានលើការរកសេវាថែទាំសុខភាព និងការសហការអន្តរាគមន៍នៅតាមគ្រឹះស្ថានសិក្សា ព្រមទាំងយន្តការសម្រួលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នៅមិនទាន់រលូននិងប្រើប្រាស់អស់លទ្ធភាពក្នុងការរៀបចំផែនការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយស្តីពីសុខភាពសិក្សា។ កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានចេញសារាចរណែនាំ ស្តីពីតួនាទី ភារកិច្ចរបស់សុខភាពសិក្សានៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា ព្រមទាំងបានបង្កើតក្រុមការងារបច្ចេកទេសជាច្រើនទៀតដូចជា គណៈកម្មាធិការអន្តរនាយកដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍និងគ្រឿងញៀន ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ ក្រុមការងារបច្ចេកទេសស្តីពីទឹកស្អាតនិងអនាម័យនៅតាមសាលារៀន។ល។ ក្នុងគោលបំណងជំរុញការអនុវត្តការងារសុខភាពសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន ពិសេសកៀរគរការចូលរួមពីអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង និងភាគីពាក់ព័ន្ធដទៃទៀត។

តែទោះជាយ៉ាងណាក្តីក៏យន្តការទាំងនោះ ភាគច្រើនមានត្រឹមកម្រិតក្របខណ្ឌក្រសួងនិងថ្នាក់រាជធានី ខេត្ត ដោយការចូលរួមមិនទាន់បានទូលំទូលាយប្រកបដោយប្រសិទ្ធភាពនៅឡើយ។ ឆ្លើយតបនឹងបញ្ហានេះ រចនាសម្ព័ន្ធសុខភាពសិក្សា ចាំបាច់ត្រូវមានការកែសម្រួល ដោយមានកិច្ចសហការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងគ្រប់ភាគីពាក់ព័ន្ធ ពិសេសត្រូវពង្រឹងរចនាសម្ព័ន្ធសុខភាពសិក្សានៅថ្នាក់រាជធានី ខេត្ត ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងថ្នាក់គ្រឹះស្ថានសិក្សាផ្ទាល់ ព្រមទាំងរៀបចំបន្ទីការងារសុខភាពសិក្សាទៅក្នុងផែនការអភិវឌ្ឍក្រសួង ស្ថាប័ន រហូតដល់គ្រឹះស្ថានសិក្សា ក្នុងគោលបំណងប្រមូលធនធាន ដើម្បីធ្វើឱ្យសម្រេចនូវគោលដៅលើកកម្ពស់សុខភាពសិក្សាគ្រប់ជ្រុងជ្រោយ។

## ១.៣- បញ្ហាអាទិភាព

បុគ្គលិកអប់រំនិងអ្នកសិក្សាមានសុខភាពល្អជាផលនៃអន្តរកម្ម ដែលបានពីការរៀបចំសេវាសុខភាពសិក្សាគ្រប់ជ្រុងជ្រោយនៅតាមគ្រឹះស្ថានសិក្សា ព្រមទាំងការត្រៀមសកម្មភាពបុរេសកម្ម ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់អវិជ្ជមាននៃបម្រែបម្រួលអាកាសធាតុ សាកលភាវូបនីយកម្ម និងការពតត្បាតជំងឺឆ្លងដោយសារចលនាប្រជាជនជាដើម។ ផ្អែកស្ថានភាពខាងលើ មានការងារជាច្រើនដែលត្រូវបន្តធ្វើ និងត្រូវពង្រឹងបន្ថែម ដើម្បីធានាឱ្យគ្រឹះស្ថានសិក្សាក្លាយជាមជ្ឈមណ្ឌលប្រកបដោយមេត្រីភាព ផាសុកភាព និងសុវត្ថិភាព ពិសេសធានាឱ្យបុគ្គលិកអប់រំនិងអ្នកសិក្សាបំពេញតួនាទីបានពេញលេញក្នុងការបង្រៀននិងរៀនប្រកបដោយគុណភាព បរិយាបន្ន សមធម៌ និងលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

តែទោះជាយ៉ាងណាក៏ដោយ ដោយធនធានមានកម្រិត យើងមិនអាចដោះស្រាយបញ្ហាទាំងអស់បានព្រមៗគ្នានោះទេ ហេតុនេះអាទិភាពចាំបាច់មួយចំនួនត្រូវបានកំណត់ជាបឋមនិងបន្តបន្ទាប់ជាជំហានៗដូចខាងក្រោម៖

